00364838

E153

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 08 / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Fuy

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ

ដាក់ទៅ: អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃដាក់: ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩

ភាគីអ្នកដាក់: សហព្រះរាជអាជ្ញា

ភាសាដើម: អង់គ្លេស

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 21 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Fuy

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ** **សាធារណៈ:**
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីច្បាប់សារធាតុជាធរមាន ស្របតាមវិធាន៩២**

---

**អ្នកដាក់ឯកសារ:**

**ការិ.សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

**មេធាវីជនជាប់ចោទ**

លោក ការ សាវុត្ថ

លោក François ROUX

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

E153

*សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ជ*

| | | |
|---|---|---|
| លោក Vincent de WILDE | **ជនជាប់ចោទឈ្មោះ** | គីម ម៉េងឃី |
| លោក សេង ប៊ុនឃាង | កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" | ម៉ុច សុវណ្ណារី |
| លោក Anees AHMED | | Silke STUDZINSKY |
| | | Martine JACQUIN |
| | | Philippe CANONNE |
| | | ទី ស្រីនណា |
| | | Pierre Olivier SUR |
| | | Alain WERNER |
| | | Brianne McGONIGLE |
| | | Annie DELAHAIE |
| | | ElizabethRABESANRATANA |
| | | Karim KHAN |
| | | Fabienne TRUSSESNAPROUS |

**មាតិកា**

**សេចក្តីផ្តើម** ....................................................................................... ៥

**ច្បាប់ជាធរមាន**....................................................................................... ៥

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**....................................................................... ៦

*លក្ខខណ្ឌតម្រូវនៃយុត្តាធិការ*....................................................................... ៨

១. ដោយទូលំទូលាយ ឬជាប្រព័ន្ធ....................................................................... ៨

២. ការវាយប្រហារ....................................................................... ១០

៣. សំដៅប្រឆាំងប្រជាជនស៊ីវិល....................................................................... ១១

៤. មូលហេតុរើសអើង....................................................................... ១២

៥. ការដឹងឮអំពីការវាយប្រហារ....................................................................... ១៣

*បទល្មើសជាក់លាក់*....................................................................... ១៣

១. ការដាក់ក្នុងមន្ទីរឃុំឃាំង....................................................................... ១៣

២. អំពើអមនុស្សធម៌ផ្សេងៗទៀត....................................................................... ១៤

៣. ការធ្វើឱ្យទៅជាទាសករ....................................................................... ១៦

៤. ការធ្វើទារុណកម្ម....................................................................... ១៦

៥. ការធ្វើមនុស្សឃាត....................................................................... ១៧

៦. ការសម្លាប់រង្គាល....................................................................... ១៨

៧. ការធ្វើទុក្ខបុកម្នេញ....................................................................... ១៩

**អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ**....................................................................... ២១

*លក្ខខណ្ឌតម្រូវនៃយុត្តាធិការ*....................................................................... ២២

១. ជម្លោះប្រដាប់អាវុធអន្តរជាតិ....................................................................... ២២

២. ជនដែលត្រូវទទួលបានការការពារ....................................................................... ២៣

៣. ការដឹងឮអំពីកាលៈទេសៈពិតជាក់ស្តែង....................................................................... ២៤

*បទល្មើសជាក់លាក់*....................................................................... ២៥

១. ការបង្ខាំងប្រជាជនស៊ីវិលដោយខុសច្បាប់....................................................................... ២៥

២. អំពើដកហូតសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវ និងទៀងទាត់....................................................................... ២៥

៣. ចេតនាធ្វើឱ្យរងការឈឺចាប់ដ៏ធំធេង ឬឱ្យមានរបួសស្នាមធ្ងន់ធ្ងរដល់រូបរាងកាយ ឬសុខភាព............២៦

៤. ការធ្វើទារុណកម្ម ឬប្រព្រឹត្តិកម្មអមនុស្សធម៌..........................................................២៧

៥. ការធ្វើមនុស្សឃាតដោយចេតនា..........................................................២៨

**ឧក្រិដ្ឋកម្មជាតិ**..........................................................២៨

១. ការធ្វើទារុណកម្ម..........................................................២៨

២. ការធ្វើមនុស្សឃាត..........................................................២៨

**ការទទួលខុសត្រូវ**..........................................................២៩

*១. បានប្រព្រឹត្ត..........................................................៣០*

ការប្រព្រឹត្តិដោយផ្ទាល់..........................................................៣០

តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម..........................................................៣១

*២. បានបញ្ជា..........................................................៣៩*

*៣. បានធ្វើផែនការ..........................................................៤១*

*៤. បានញុះញង់..........................................................៤២*

*៥. បានជួយជ្រោមជ្រែង..........................................................៤៣*

*៦. ការទទួលខុសត្រូវរបស់ថ្នាក់លើ..........................................................៤៥*

**សេចក្តីសន្និដ្ឋាន**..........................................................៤៩

00364842

E153

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ជ*

## សេចក្តីផ្តើម

១. វិធាន៨៧.១ នៃវិធានផ្ទៃក្នុង ដាក់បន្ទុកសហព្រះរាជអាជ្ញា ឲ្យបញ្ជាក់ភស្តុតាងប្រឆាំងនឹងជនជាប់ចោទ **ឌុច** ឲ្យហួសពីវិមតិសង្ស័យ ។ ដើម្បីបំពេញឲ្យបាននូវបន្ទុកនេះ និងដោយមានទស្សនៈដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការស្រាវជ្រាវស្វែងរកការពិតរបស់ខ្លួន សហព្រះរាជអាជ្ញា ដាក់សេចក្តីសន្និដ្ឋានជាលាយល័ក្ខណ៍អក្សរនេះ ដើម្បីដាក់ច្បាប់ជាធរមានចំពោះបទឧក្រិដ្ឋទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ការដាក់ឯកសារនេះ ដូចមាននៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា នឹងជួយដល់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធចំពោះភស្តុតាងទាំងឡាយដែលបានស្តាប់នៅពេលសវនាការ ។

២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចេញដោយសហចៅក្រមស៊ើបអង្កេត ដែលបានកែប្រែដោយអង្គបុរេជំនុំជម្រះ ចោទប្រកាន់ ឌុច: ១) **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលអាចផ្តន្ទាទោសតាមមាត្រា ៥, មាត្រា ២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, ២) **អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩** ដែលអាចផ្តន្ទាទោសតាមមាត្រា ៦, មាត្រា ២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង ៣) អំពើរំលោភលើ **ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦** ដែលអាចផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), មាត្រា ២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

៣. សេចក្តីសន្និដ្ឋាននេះ ដាក់ច្បាប់ពាក់ព័ន្ធនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចំពោះឧក្រិដ្ឋកម្មទាំងបីប្រភេទខុសៗគ្នាទាំងនេះ[1] ។

## ច្បាប់ជាធរមាន

[1] សហព្រះរាជអាជ្ញាលើកយោងច្បាប់នៅថ្ងៃនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ។ ប្រភពច្បាប់យោងដែលបានលើកយោងនៅក្នុងការដាក់ឯកសារនេះ មានរួចជាស្រេចហើយនៅក្នុងសំណុំរឿងលេខ ០០១ ដែលដាក់ភ្ជាប់ជាឧបសម្ព័ន្ធ ទៅនឹង វិធាន៦៦ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹង កាំង ហ្គេចអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨, D 96 ។ ស្របគ្នានេះដែរ មិនមានតារាងប្រភពច្បាប់យោង ត្រូវបានដាក់ជាមួយនឹងការដាក់សេចក្តីសន្និដ្ឋាននេះទេ ។

៤. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវជាផ្នែកមួយនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងត្រូវបានគេយកទៅអនុវត្តជាចំបង នៅសាលាក្តីអន្តរជាតិនានា។ ទោះបីជានៅប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋជាច្រើនបានបញ្ចូលកាន់តែច្រើនឡើងនូវធាតុផ្សំនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួនក៏ដោយ យុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ និងកូនកាត់ដែលត្រូវបានបង្កើតឡើងចាប់ពីសង្គ្រាមលោកលើកទីII គឺជាប្រភពនៃសិទ្ធិអំណាចដ៏សំខាន់ស្តីអំពីធាតុផ្សំនៃបទល្មើសទាំងនេះ។

៥. សេចក្តីសម្រេចរបស់តុលាការយោធាអន្តរជាតិនៅនូរ៉ំប៊ឺក (IMT) តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា (IMTFE) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា (ICTR) តុលាការពិសេសសម្រាប់សេរ៉ាលីអូន (SCSL) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ជាសេចក្តីសម្រេច ដែលពាក់ព័ន្ធជាងគេបង្អស់សម្រាប់ការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអនុសញ្ញាទីក្រុងហ្សឺណែវ នៅ អ.វ.ត.ក។ តាមសហព្រះរាជអាជ្ញាដឹង យុត្តិសាស្ត្រកម្ពុជាមិនមានទេ ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ពុំមែនជាឧក្រិដ្ឋកម្មដែលតុលាការនៃព្រះរាជាណាចក្រកម្ពុជាធ្លាប់បានកាត់សេចក្តីពីមុនមកទេ។

## ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៦. មាត្រា៥នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ផ្តល់សិទ្ធិដល់ អ.វ.ត.ក ឱ្យកាត់ទោសបុគ្គលទាំងឡាយណា ដែលត្រូវបានសង្ស័យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បទល្មើសពិសេសដែលមាននៅក្នុងមាត្រា៥ រួមមានការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ប្រហាក់ប្រហែលគ្នានេះដែរ

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី[2] (ICTY) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា[3] (ICTR) តុលាការពិសេសសម្រាប់សេរាលីអូន[4] (SCSL) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ[5] (ICC) សុទ្ធតែជាតុលាការ ដែលមានសិទ្ធិអំណាចផ្តន្ទាទោសបទឧក្រិដ្ឋទាំងអស់ ដូចមានចែងក្នុងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ពោលគឺ ការធ្វើមនុស្សឃាត[6] ការសម្លាប់រង្គាល[7] ការធ្វើឱ្យទៅជាទាសករ[8] ការដាក់ក្នុងមន្ទីរឃុំឃាំង[9] ការធ្វើទារុណកម្ម[10] ការធ្វើទុក្ខបុកម្នេញ

---

[2] ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី S.C Res 827 ឯកសារអង្គការសហប្រជាជាតិ S/Res/827 (1993) មាត្រា៥ (ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី)។

[3] ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា S.C. Res.955 ឯកសារអង្គការសហប្រជាជាតិ S/Res/ 955 (១៩៩៤) មាត្រា៣ ("ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា")។

[4] ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន S.C.Res.1315 ឯកសារអង្គការសហប្រជាជាតិ S/Res/1315 (២០០០) មាត្រា២ ("ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន")។

[5] ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារអង្គការសហប្រជាជាតិ A/CONF. 183/9 (១៩៩៨) មាត្រា៧ ("ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម")។

[6] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា៥ (ក) ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា មាត្រា៣ (ក) ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន មាត្រា២ (ខ) ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧ (ក)។

[7] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា៥ (ខ)។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា មាត្រា៣ (ខ)។ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន មាត្រា២ (ខ) ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧ (ខ)។

[8] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា៥ (គ)។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា មាត្រា៣ (គ)។ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ សេរ៉ាឡេអូន មាត្រា២ (គ) ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧ ៧(គ)។

[9] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា៥ (ង)។ ច្បាប់លក្ខន្តិកៈនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា មាត្រា៣ (ង)។ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន មាត្រា ២ (ង) ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧ (ង)។

[10] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មាត្រា៥ (ច)។ ច្បាប់លក្ខន្តិកៈនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា មាត្រា ៣ (ច)។ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន មាត្រា ២ (ច) ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧(ច)។

ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[11] និងអំពើអមនុស្សធម៌ ផ្សេងៗទៀត[12]។ ធាតុផ្សំនៃបទល្មើសនីមួយៗនៃបទល្មើសទាំងនោះត្រូវពិភាក្សាខាងក្រោម។

៧. ដើម្បីឲ្យការប្រព្រឹត្តិបទល្មើសទាំងនេះបង្កើតបានជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធាតុផ្សំយុត្តាធិការជាក់លាក់មួយចំនួន ជាធាតុផ្សំមិនអាចខ្វះបាន[13]។ បទល្មើសជាក់លាក់ត្រូវប្រព្រឹត្តរួចហើយ: (១) ជាផ្នែកមួយនៃ (២) ដោយទូលំទូលាយ ឬជាប្រព័ន្ធ (៣) វាយប្រហារ (៤) សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល (៥) ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។

## លក្ខខណ្ឌតម្រូវនៃយុត្តាធិការ
## ១. ដោយទូលំទូលាយ ឬជាប្រព័ន្ធ

[11] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មាត្រា៥ (ជ)។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា មាត្រា៣ (ជ)។ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន មាត្រា២ (ជ) ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧ (ជ)។

[12] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា៥ (ឈ)។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា មាត្រា ៣ (ឈ)។ ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន មាត្រា២ (ឈ) ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៧ (ជ)។

[13] ការទាមទារផ្នែកយុត្តាធិការមិនមែនជាធាតុផ្សំនៃបទល្មើសណាមួយទេ ប៉ុន្តែបទល្មើសនោះត្រូវតែជាផ្នែកមួយនៃការវាយប្រហារសមស្របតាមការទាមទាររបស់យុត្តាធិការនោះ។ *សូមមើល Deronjic* សាលក្រម តុលាការឧក្រិដ្ឋកម្ម អន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី តុលាការសាលាឧទ្ធរណ៍ សំណុំរឿងលេខ IT-02-61 ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ១០៩ ("សាលដីកា *Deronjic*") "ការទាមទារនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ យកមកអនុវត្តលើការវាយប្រហារនោះប៉ុណ្ណោះ និងមិនមែនលើទង្វើបុគ្គលនៃជនត្រូវចោទនោះទេ"។ *វគ្គអាជ្ញា ទល់នឹង Dario Kordic & Mario Cerkez* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការសាលាឧទ្ធរណ៍ សំណុំរឿងលេខ IT-95-14A ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ៩៤ ("សាលដីកា *Kordic*") "មានតែការវាយប្រហារតែប៉ុណ្ណោះ ដែលត្រូវមានលក្ខណៈជាប្រព័ន្ធ មិនមែនទង្វើបុគ្គលនៃជនត្រូវចោទនោះទេដែលត្រូវមានលក្ខណៈទូទៅ ឬជាប្រព័ន្ធនោះ"។ *វគ្គអាជ្ញា ទល់នឹង Kayishema និង Ruzindana* សាលក្រម អង្គជំនុំជម្រះតុលាការពិសេសសម្រាប់សេរ៉ាឡេអូន សំណុំរឿងលេខ តុលាការពិសេសសម្រាប់សេរ៉ាលីអូន-95-1-T ថ្ងៃទី២១ ខែឧសភា ឆ្នាំ ១៩៩៩ កថាខ័ណ្ឌ១៣៥ ("សាលក្រម *Kayishema*")។

៨. ការវាយប្រហារត្រូវតែទូលំទូលាយ ឬជាប្រព័ន្ធ។ លក្ខខណ្ឌទាំងនេះគឺបែកចេញពីគ្នា[14]។ ពាក្យ "ទូលំទូលាយ" មានន័យថា "ជាការវាយប្រហារទ្រង់ទ្រាយធំ និងមានមុខសញ្ញាច្រើន"[15] និងអាចត្រូវបានបង្កើតឡើងដោយ "អនុភាពនៃការបូកបន្ថែមនៃអំពើអមនុស្សធម៌ ឬអនុភាពតែមួយនៃអំពើអមនុស្សធម៌តែមួយ ដែលមានវិសាលភាពធំធេង[16]។ ដូច្នេះការវាយប្រហារអាចជា អំពើតែមួយគត់ តែជាអំពើដែលមានផលប៉ះពាល់ខ្លាំង ឬផលប៉ះពាល់លើមនុស្សមួយចំនួនធំ។

៩. ពាក្យ "ជាប្រព័ន្ធ" មិនចាំបាច់ទាល់តែមានការវាយប្រហារកម្រិតធំទេ ប៉ុន្តែទាក់ទងទៅនឹង "ចរិតនៃអំពើហិង្សាដែលគ្រោងទុកជាមុន និងភាវនីយភាពនៃ ការកើតឡើងដោយចៃដន្យរបស់វា"[17]។ អំពើហិង្សាអាចត្រូវបានគេចាត់ទុកថា ជាអំពើហិង្សាមានលក្ខណៈជាប្រព័ន្ធ នៅពេលដែលមានភស្តុតាងបញ្ជាក់ថា "អំពើព្រហ្មទណ្ឌប្រហាក់ប្រហែលគ្នាបានកើតឡើងជាច្រើនលើកច្រើនសារ និងពុំមែនដោយការចៃដន្យ"[18]។

១០. សូចនាករ(ការចង្អុលបង្ហាញ) ផ្សេងៗទៀតដែលអាចបញ្ជាក់អំពីការកើតមាននូវការវាយប្រហារដោយទូលំទូលាយ ឬជាប្រព័ន្ធគឺជា "ផលវិបាកនៃការវាយប្រហារទៅលើគោលដៅប្រជាជន ចំនួនជនរងគ្រោះ ចរិតនៃអំពើទាំងនោះ លទ្ធភាពចូលរួមរបស់មន្ត្រី ឬអាជ្ញាធរ ឬលំនាំផ្សេងទៀតនៃបទឧក្រិដ្ឋ

---

[14] *រដ្ឋអាជ្ញា ទល់នឹង Dragoljub Kunarac Radomir Kovac & Zoran Vukovic* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការសាលាឧទ្ធរណ៍ សំណុំរឿងលេខ IT-96-23 & IT-96-23/1-A ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ៩៣ ("សាលដីកា *Kunarac*") *សូមមើល រដ្ឋអាជ្ញា ទល់នឹង Brima Kumara* & សាលក្រម *Kanu* សាលក្រមនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន សំណុំរឿងលេខ សាលក្រម នៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន -04-16-T ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ២១៥ ("សាលក្រម *Brima* ") ។

[15] *Kordic* សាលដីកា កថាខណ្ឌ ៩៤។

[16] *រដ្ឋអាជ្ញា ទល់នឹង Vidoje Blagojevic & Dragon Jokic* សាលក្រ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-02-60-T ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខ័ណ្ឌ៥៤៥ ("សាលក្រម *Blagojevic*")។

[17] *Kordic* សាលដីកា កថាខ័ណ្ឌ ៩៤។

[18] *Kordic* សាលដីកា កថាខ័ណ្ឌ ៩៤។

ដែលគេអាចកត់សម្គាល់បាន"[19]។ ការវាយប្រហារដោយទូលំទូលាយ ឬជាប្រព័ន្ធមិនទាមទារឱ្យមានផែនការ ឬគោលនយោបាយអ្វីទេ ប៉ុន្តែអត្ថិភាពនៃផែនការ ឬគោលនយោបាយទាំងនោះកាន់តែជាភស្តុតាងបញ្ជាក់កាន់តែច្បាស់អំពីចរិតនៃការវាយប្រហារ[20]។

## ២. ការវាយប្រហារ

១១. អំពើដែលចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាល់តែអំពើនោះបានប្រព្រឹត្ត ជាផ្នែកមួយនៃ "ការវាយប្រហារ"។ ការវាយប្រហារត្រូវបានកំណត់អត្ថន័យថាជា "ទង្វើដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិអំពើហិង្សា[21]" ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើឱ្យទៅជាទាសករ។ "ការវាយប្រហារ" ដែលអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនចាំបាច់ជាការវាយប្រហារយោធាឬជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធទេ[22]។ ការវាយប្រហារអាចមានលក្ខណៈអហិង្សាដូចជាការដាក់ឱ្យមានប្រព័ន្ធអាប៉ាថេត ឬការបង្ក្រាប ឬការដាក់ការកៀបសង្កត់ ទៅលើប្រជាជនឱ្យប្រព្រឹត្តតាមរបៀបណាមួយ ជាពិសេស "ប្រសិនបើជាបានបង្កជាទ្រង់ទ្រាយធំ ឬមានលក្ខណៈជាប្រព័ន្ធ"[23]។

---

[19] សាលដីកា *Kunarac* កថាខ័ណ្ឌ៩៥ *សូមមើល រដ្ឋអាជ្ញា ទល់នឹង Fatmir Limaj Haradin Bala & Isak Musliu* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-03-66-T ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខណ្ឌ ១៨៣ ("សាលក្រម *Limaj*")។

[20] សាលដីកា *Kunarac* កថាខណ្ឌ ៩៨។

[21] សាលក្រម *Blagojevic* កថាខណ្ឌ ៥៤៣។

[22] សាលក្រម *Brima* កថាខណ្ឌ ២១៤ *សូមមើល រដ្ឋអាជ្ញាទល់នឹង Mitar Vasiljevic* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-98-32-T ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ៣០ ("សាលក្រម *Vasiljevic*")។

[23] *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu* សាលក្រម តុលាការពិសេសសម្រាប់សេរ៉ាឡេអូន តុលាការសាលាឧទ្ធរណ៍ សំណុំរឿងលេខ តុលាការពិសេសសម្រាប់សេរ៉ាឡេអូន-96-4-T ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៥៨១ ("សាលដីកា *Akayesu*") *សូមមើល Kunarac* សាលដីកា កថាខណ្ឌ៨៦ "ការវាយប្រហារក្នុងបរិបទ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនមែនកំណត់ត្រឹមតែការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ពោលគឺវារាប់បញ្ចូលទាំងការធ្វើបាបទាំងឡាយណាទៅលើប្រជាជនស៊ីវិល"។

## ៣. សំដៅប្រឆាំងប្រជាជនស៊ីវិល

១២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែ "សំដៅប្រឆាំង" ប្រជាជនស៊ីវិល ដែលកំណត់ថា ប្រជាជនស៊ីវិល គឺជាគោលដៅចំបងនៃការវាយប្រហារ[24]។ កត្តាដែលកំណត់ថាតើការវាយប្រហារសំដៅប្រឆាំងប្រជាជនស៊ីវិល ឬមិនសំដៅប្រជាជនស៊ីវិលរួមមាន: មធ្យោបាយនិងវិធីសាស្ត្រ ដែលប្រើប្រាស់នៅក្នុងការវាយប្រហារ ឋានៈជនរងគ្រោះ ចំនួនជនរងគ្រោះ លក្ខណៈរើសអើងនៃការវាយប្រហារ ចរិតនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ភាពស្វិតស្វាញរបស់អ្នកវាយប្រហារនៅពេលនោះ និងវិសាលភាពដែលកម្លាំងវាយប្រហារអាចត្រូវបានគេនិយាយថា បានប្រតិបត្តិតាម ឬមានបំណងប្រតិបត្តិតាមលក្ខខណ្ឌប្រុងប្រយ័ត្ននៃច្បាប់សង្គ្រាម[25]។

១៣. ពាក្យ "ជនស៊ីវិល" សំដៅដល់ "ជនដែលមិនចូលរួមក្នុងអរិភាព រួមមានសមាជិកកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធរបស់ខ្លួន និងជនអសមត្ថភាពក្នុងការប្រយុទ្ធ ដោយសារជម្ងឺ របួស ការជាប់

---

[24] *រដ្ឋអាជ្ញា ទល់នឹង* *Mile Mrksic, Miroslav Radic & Veselin Sljivancanin* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-95-13/1-T ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ៤៤០ ("សាលក្រម *Mrksic*") សាលដីកា *Kunarac* កថាខណ្ឌ៩១ *សូមមើល* សាលដីកា *Kordic* កថាខ័ណ្ឌ៩៦ សាលក្រម *Limaj* កថាខណ្ឌ១៨៥ *រដ្ឋអាជ្ញា ទល់នឹង* *Radoslav Brdjanin* សាលក្រម អង្គជំនុំជម្រះ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ. IT-99-36-T ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ១៣៤ ("សាលក្រម *Brdjanin*") *រដ្ឋអាជ្ញា ទល់នឹង Stanislav Galic*, សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី អង្គជំនុំជម្រះ សំណុំរឿងលេខ IT-98-29-T, ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ កថាខ័ណ្ឌ១៤២ ("សាលក្រម*Galic*") *រដ្ឋអាជ្ញា ទល់នឹង Milomir Stakic* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី អង្គជំនុំជម្រះ សំណុំរឿងលេខ IT-97-24-Tថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣កថាខណ្ឌ៦២៤ (*"Stakic* សាលក្រម) *រដ្ឋអាជ្ញា ទល់នឹង Mladen Naletilic aka "Tuta" and Vinko Martinovic aka "Stela"* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី អង្គជំនុំជម្រះ សំណុំរឿងលេខ IT-98-34-T ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ២៣៥ ("សាលក្រម *Naletilic*")។

[25] សាលក្រម *Mrksic* កថាខណ្ឌ ៤៤០ សាលដីកា *Kunarac* កថាខណ្ឌ៩០ រដ្ឋអាជ្ញា ទល់នឹង *Tihomir Blaskic* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការសាលាឧទ្ធរណ៍ សំណុំរឿងលេខ IT-95-14-A ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១០៦ ("សាលដីកា *Blaskic*")។

ឃុំឃាំង ឬមូលហេតុផ្សេង"[26]។ ដូច្នេះសមាជិក ឬអតីតសមាជិកយោធា ត្រូវចាត់ទុកថា ជាជនស៊ីវិលចំពោះមូលហេតុឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បើសិនជាមិនបានចូលរួមយ៉ាងសកម្មនៅក្នុងអរិភាពណាមួយក្នុងអំឡុងពេលវាយប្រហារនោះទេ។ ដូចគ្នាដែរ ប្រសិនបើពួកគេស្ថិតនៅក្នុងការឃុំឃាំង នៅពេលនោះពួកគេក្លាយជាជនរងគ្រោះនៃការវាយប្រហារ។ "ប្រជាជនស៊ីវិល" មិនចាំបាច់តម្រូវឱ្យរួមបញ្ចូលប្រជាពលជនទាំងមូលនៃតំបន់ភូមិសាស្ត្រណាមួយ ដែលទទួលរងការវាយប្រហារនោះទេ[27]។ ប្រហាក់ប្រហែលគ្នានេះដែរ "ប្រជាជនស៊ីវិល" អាចរួមបញ្ចូលជនមិនមែនជាជនស៊ីវិលឱ្យតែប្រជាជននៅក្នុងក្រុមនោះភាគច្រើនលើសលុប គឺជាប្រជាជនស៊ីវិល[28]។

### ៤. មូលហេតុរើសអើង

១៤. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិកំណត់ថា ការវាយប្រហារមានលក្ខណៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិលុះណាតែការវាយប្រហារនោះមានលក្ខណៈរើសអើង។ ការរើសអើងនេះត្រូវផ្អែកលើមូលហេតុជាតិសាសន៍ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា[29]។ ធាតុផ្សំនេះសំដៅដល់លក្ខណៈនៃការវាយប្រហារ តែមិនមែនជាធាតុផ្សំនៃបទល្មើសជាក់លាក់ណាមួយនោះទេ[30]។

---

[26] សាលក្រម *Blagojevic* កថាខណ្ឌ៥៤៤។ សាលក្រម *Brima* កថាខណ្ឌ ២១៦ *ដកស្រង់ពី រដ្ឋអាជ្ញា ទល់នឹង* *Jean-Paul Akayesu* សាលក្រម និងការកាត់ទោស តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា សំណុំរឿងលេខ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា-96-4-T ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ៥៨២ ("សាលក្រម និងការកាត់ទោស *Akayesu*")។

[27] សាលដីកា *Kunarac* កថាខណ្ឌ ៩០។

[28] សាលក្រម *Mrksic* កថាខណ្ឌ ៤៤២ ដកស្រង់ពី *រដ្ឋអាជ្ញា ទល់នឹង* *Goran Jelisic* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-95-10-T, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៥៤ ("សាលក្រម *Jelisic*") *រដ្ឋអាជ្ញា ទល់នឹង* *Zoran Kupreskic Mirjan Kupreskic Vlatko Kupreskic Drago Josipovic Dragan Papic & Vladimi Santic aka "Vlado"* សាលក្រម តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-95-16-T ថ្ងៃទី១៤ ខែមករា ឆ្នាំ ២០០០ កថាខ័ណ្ឌ៥៤៧-៥៤៩ ("សាលក្រម *Kupreskic*) សាលក្រម *Blago jevic* កថាខណ្ឌ៥៤៤។

[29] ច្បាប់ស្តីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា ៥ ("ច្បាប់ ECCC")។

[30] សាលដីកា *Akayesu* កថាខណ្ឌ៤៦៦ "ការរើសអើង គឺមិនមែនជាលក្ខខណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗ លើកលែងតែកន្លែងណាដែលពាក់ព័ន្ធដល់ការធ្វើទុក្ខបុកម្នេញ"។ *រដ្ឋអាជ្ញា ទល់នឹង* *Baglishema*

## ៥. ការដឹងឮអំពីការវាយប្រហារ

១៥. ដើម្បីឲ្យបទល្មើសមួយជាផ្នែកមួយនៃអំពើឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ចារីត្រូវតែបានដឹងអំពីអំពើនៃការវាយប្រហារនោះ ហើយគាត់ត្រូវដឹងថា អំពើរបស់គាត់ជាផ្នែកមួយនៃការវាយប្រហារ[31]។ ការដឹងយ៉ាងលំអិតអំពីការវាយប្រហារគឺមិនចាំបាច់ទេ[32] តែវានឹងបំពេញយ៉ាងគ្រប់គ្រាន់ បើសិនជាចារីបានដឹងអំពីបរិបទទូទៅនៃការវាយប្រហារ ដែលសកម្មភាពរបស់គាត់បានចាប់ផ្ដើមធ្វើក្នុងការវាយប្រហារនោះ[33]។ បំណងនៃការប្រព្រឹត្តិរបស់ចារីមិនពាក់ព័ន្ធទេ[34] ហើយក៏មិនចាំបាច់ថា ចារីបានយល់ព្រមឲ្យធ្វើការវាយប្រហារនោះដែរ[35]។

## បទល្មើសជាក់លាក់

### ១. ការដាក់ក្នុងមន្ទីរឃុំឃាំង

១៦. ការដាក់ក្នុងមន្ទីរឃុំឃាំងដែលចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យបង្ហាញអំពីធាតុផ្សំចំនួនបី (៣) ដែលមានដូចតទៅនេះៈ (១) សេរីភាពរបស់បុគ្គលត្រូវបានដកហូត (២) ការដកសិទ្ធិសេរីភាពគឺធ្វើតាមទំនើងចិត្ត និង(៣) អំពើ ឬការខកខានមិនបានធ្វើអំពើ ដែលបណ្ដាលឱ្យមានការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលនោះ ដែលជនជាប់ចោទឬជនណាម្នាក់ឬច្រើននាក់ផ្សេងទៀត ដែលជនជាប់ចោទគឺជាអ្នកត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌជាអ្នកបានប្រព្រឹត្ត ដោយមានចេតនា

---

សាលក្រមតុលាការពិសេសសម្រាប់សេរ៉ាឡេអូន សំណុំរឿងលេខ តុលាការពិសេសសម្រាប់ សេរ៉ាឡេអូន-95-1A-T ០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៨១ (សាលក្រម *Baglishema*)។

[31] សាលដីកា *Kunarac* កថាខណ្ឌ៩៩ សាលដីកា *Kordic* កថាខណ្ឌ៩៩ សាលក្រម *Kayishema* កថាខ័ណ្ឌ១៣៣-១៣៤។

[32] សាលដីកា *Kunarac* កថាខណ្ឌ១០២ "ការទាមទារថាជនត្រូវចោទបានដឹងឮអំពីការវាយប្រហារ គឺមិនចាំបាច់ទាល់តែជននោះបានដឹងឮលម្អិតអំពីការវាយប្រហារនោះទេ"។ សាលក្រម *Blagojevic* កថាខណ្ឌ៥៤៨ "លក្ខខណ្ឌតម្រូវថាជនត្រូវចោទមានចេតនាឧក្រិដ្ឋ ... គឺមិនចាំបាច់ថាជននោះត្រូវដឹងឮលម្អិត អំពីការវាយប្រហារ នោះទេ"។

[33] សាលក្រម *Limaj* កថាខណ្ឌ ១៩០។

[34] សាលដីកា *Limaj* កថាខ័ណ្ឌ ១៩០។

[35] សាលដីកា *Limaj* កថាខ័ណ្ឌ ១៩០។

ដើម្បីដកហូតសិទ្ធិសេរីភាពជារូបវន្តរបស់បុគ្គលតាមទំនើងចិត្ត ឬជនជាប់ចោទមានហេតុផលសមស្របដែលត្រូវតែដឹង ថាអំពើឬការខកខានមិនបានធ្វើអំពើរបស់ខ្លួននោះមុខជានឹងមានភាវនីយភាពឈានដល់ការហូតសិទ្ធិសេរីភាពជារូបវន្តរបស់បុគ្គលតាមទំនើងចិត្តជាពុំខានឡើយ[36]។ ការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវចាត់ទុកថាជាការធ្វើតាមទំនើងចិត្ត នៅពេលដែលការដាក់ក្នុងមន្ទីរឃុំឃាំងនោះមិនមានមូលដ្ឋានច្បាប់ដើម្បីបញ្ជាក់ឱ្យបានត្រឹមត្រូវ និងដោយមិនស្របតាមតាមនីតិវិធីត្រឹមត្រូវតាមច្បាប់[37]។ ជនទាំងឡាយដែលទទួលខុសត្រូវពន្ធនាគារ ដែលដឹងយ៉ាងច្បាស់ថា អ្នកជាប់ឃុំឃាំងត្រូវបានឃុំឃាំងដោយខុសច្បាប់ គឺជាការប្រព្រឹត្តអំពើដាក់មនុស្សក្នុងមន្ទីរឃុំឃាំង ដែលអាចចាប់បង្ខំឱ្យទទួលខុសត្រូវពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[38]។

## ២. អំពើអមនុស្សធម៌ផ្សេងៗទៀត

១៧. "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាប្រភេទសំណល់មួយ (a residual category) ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលធ្វើឱ្យអំពើអមនុស្សធម៌ ត្រូវមានទោសជាបទព្រហ្មទណ្ឌដែលមានស្ថានទម្ងន់ទោសប្រហាក់ប្រហែលគ្នានឹងស្ថានទម្ងន់ទោសនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានរៀបរាប់ជាក់លាក់រួចមកហើយ[39]។ តម្រូវចាំបាច់ឱ្យមានធាតុផ្សំដូចខាងក្រោមនេះ ដើម្បីអាចឱ្យបានចាត់ទុកអំពើណាមួយថាជា អំពើអមនុស្សធម៌បាន: (១) ជនរងគ្រោះ ត្រូវតែបានទទួលរងនូវការឈឺចាប់យ៉ាងធ្ងន់ធ្ងរខាងផ្លូវកាយ ឬនូវការខូចខាតខាងបញ្ញាស្មារតី (ដែលកម្រិតនៃភាពធ្ងន់ធ្ងរត្រូវធ្វើការវាយតម្លៃដោយផ្អែកទៅតាមករណីនីមួយៗ ដោយពិនិត្យជាក់ស្តែងទៅតាមស្ថានភាពរបស់ជនរងគ្រោះ

---

[36] សាលដីកា *Kunarac* កថាខ័ណ្ឌ៥៩។ សាលដីកា *Kordic* កថាខ័ណ្ឌ៥៩។ សាលក្រម *Kayishema* កថាខ័ណ្ឌ ១៣៣-១៣៤។

[37] *រដ្ឋអាជ្ញា ទល់នឹង Blagoje Simic Miroslav Tadic & Simo Zaric* សាលក្រមរបស់អង្គជំនុំជម្រះ សាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) សំណុំរឿងលេខ IT-95-9 ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខ័ណ្ឌ៦៤ ("សាលក្រម *Simic*")។ *សូមមើលផងដែរករណី រដ្ឋអាជ្ញា ទល់នឹង Milorad Krnojelac* សាលក្រមរបស់អង្គជំនុំជម្រះតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) សំណុំ រឿងលេខ. IT-97-25-T ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខ័ណ្ឌ ១១៥ ("សាលក្រម *Krnojelac*")។

[38] *សូមអានសេចក្តីសន្និដ្ឋាននៃសាលក្រម* *Krnojelac* កថាខ័ណ្ឌ១២៥។

[39] សាលក្រម *Blagojevic* កថាខ័ណ្ឌ៦២៥។ សាលដីកា *Kordic* កថាខ័ណ្ឌ១១៧។ សាលក្រម *Galic* កថាខ័ណ្ឌ១៥២។

ម្នាក់ៗ ។ (២) ការឈឺចាប់នោះចាំបាច់ត្រូវតែជាអំពើ ឬការខកខានមិនបានធ្វើរបស់ជនជាប់ចោទ ឬអ្នកក្រោមបង្គាប់គាត់។ ហើយ (៣) នៅពេលមានអំពើឧក្រិដ្ឋមួយត្រូវបានប្រព្រឹត្តជនជាប់ចោទ ឬអ្នកនៅក្រោមបង្គាប់របស់គាត់ពិតជាមានការជំរុញចិត្តឱ្យមានចេតនាចង់ធ្វើឱ្យជនរងគ្រោះទទួលរងការឈឺចាប់ធ្ងន់ធ្ងរខាងផ្លូវកាយ និងផ្លូវចិត្ត[40]។ ភាពធ្ងន់ធ្ងរនៃអំពើនេះត្រូវតែមាន "ទម្ងន់ប្រហាក់ប្រហែល" ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានរៀបរាប់[41] ប៉ុន្តែជនរងគ្រោះមិនចាំបាច់តម្រូវឱ្យទទួលរងការឈឺចាប់ក្នុងពេលយូរអង្វែងនោះទេ[42]។

១៨. យុត្តិសាស្ត្រដែលទាក់ទងទៅនឹងមណ្ឌលឃុំឃាំងនានា បានរកឃើញថា ការរងការខូចខាតខាងផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរដែលរួមមានការវាយដំ ការធ្វើទារុណកម្ម ហិង្សាផ្លូវភេទ ការធ្វើឱ្យអាម៉ាស់ ការយាយីបំពានផ្លូវចិត្ត និងការឃុំឃាំងក្នុងស្ថានភាពអាក្រក់ គឺជាអំពើអមនុស្សធម៌[43]។ ការវាយដំ និងការធ្វើបាបជាប្រចាំទៅលើអ្នកជាប់ឃុំឃាំងក្នុងអំឡុងពេលសួរចម្លើយពួកគេ អំពើព្រៃផ្សៃកើតមានជួនៗ និងការភ័យខ្លាចជាប្រចាំអំពីការវាយដំ ក៏ចាត់ទុកជាប្រព្រឹត្តកម្មអមនុស្សធម៌ផង[44]។

---

[40] សាលដីកា *Kordic* កថាខ័ណ្ឌ១១៧។

[41] *រដ្ឋអាជ្ញា ទល់នឹង Mitar Vasiljevic* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី (ICTY) សំណុំរឿងលេខ IT-98-32-A ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខ័ណ្ឌ១៦៥ ("សាលដីកា *Vasiljevic*")។ សាលក្រម *Blagojevic* កថាខ័ណ្ឌ៦២៧។

[42] សាលដីកា *Vasiljevic* កថាខ័ណ្ឌ១៦៥។ សាលក្រម *Blagojevic* កថាខ័ណ្ឌ៦២៧។

[43] សាលក្រម *Krnojelac* កថាខ័ណ្ឌ១៣៣។ *រដ្ឋអាជ្ញា ទល់នឹង Kvocka* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី(ICTY) សំណុំរឿងលេខ. IT-98-30/1-T, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខ័ណ្ឌ ១៦៤-១៦៥ និង៧២០ (សាលាក្រម *Kvocka*)។

[44] *រដ្ឋអាជ្ញា ទល់នឹង Aleksovski* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ អតីតយូហ្គោស្លាវី(ICTY) សំណុំរឿងលេខIT-95-14/1 ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ កថាខ័ណ្ឌ២២៨ ("សាលក្រម *Aleksovski*")។ ក្នុងករណីនេះ ទង្វើទាំងនោះបានត្រូវចាត់ទុកថាជា "ការមើលងាយដល់សេចក្តីថ្លៃថ្នូររបស់បុគ្គល"" ក្នុងមាត្រា៣ នៃច្បាប់លក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី។ រឿងនេះឆ្លុះបញ្ចាំងនូវ មាត្រា៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ។ ក្នុងសាលក្រម កថាខ័ណ្ឌ៥៤ អង្គជំនុំជម្រះយល់ឃើញថា "ការមើលងាយ ដល់សេចក្តីថ្លៃថ្នូររបស់បុគ្គល" គឺជាប្រភេទមួយនៃ "ការប្រព្រឹត្តអមនុស្សធម៌"។ អង្គជំនុំជម្រះយល់ឃើញផងដែរថា ទង្វើទាំងនោះគឺជាការបន្ថោកសេចក្តីថ្លៃថ្នូរ ឬ ការធ្វើឱ្យអាម៉ាស់។

### ៣. ការធ្វើឲ្យទៅជាទាសករ

១៩. ការធ្វើឲ្យទៅជាទាសករ ត្រូវបានកំណត់និយមន័យថា គឺជាការប្រើប្រាស់អំណាចដោយចេតនា ដើម្បីធ្វើជាម្ចាស់ទៅលើជនណាម្នាក់[45]។ ពុំមានការព្រមព្រៀង ឬឆន្ទៈនៃការសម្រេចដោយសេរីរបស់ជនរងគ្រោះទេ[46]។ កត្តានានាដែលបង្ហាញថាមានអត្ថិភាព នៃការធ្វើឲ្យទៅជាទាសករគឺ រួមមាន: "ការត្រួតត្រាទៅលើចលនាដើរហើររបស់មនុស្សមួយចំនួន ការត្រួតត្រាទៅលើបរិស្ថានខាងផ្លូវកាយ និងផ្លូវចិត្ត ការចាត់វិធានការដើម្បីទប់ស្កាត់ឬធ្វើឱ្យញញើតមិនហ៊ានរត់គេច ការបង្ខំ គំរាមកំហែងថានឹងប្រើកម្លាំង ឬការបង្ខិតបង្ខំ ពេលវេលា ការពោលអះអាងថាជាកម្មសិទ្ធិផ្តាច់មុខ ការដាក់បុគ្គលនោះឲ្យទទួលរងនូវប្រព្រឹត្តកម្មឃោរឃៅ និងការរំលោភបំពាន ការគ្រប់គ្រងផ្លូវភេទ និងពលកម្មដោយបង្ខំ"[47]។

### ៤. ការធ្វើទារុណកម្ម

២០. ការធ្វើទារុណកម្ម ដែលអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺតម្រូវឲ្យមានធាតុផ្សំចំនួនបី(៣): (១) ចាំបាច់ត្រូវមានអំពើ ឬការខកខានមិនបានធ្វើអំពើ ដែលបណ្តាលឲ្យមានការឈឺចាប់ ឬរងគ្រោះធ្ងន់ធ្ងរខាងផ្លូវកាយ ឬផ្លូវចិត្ត (២) បទល្មើសសកម្ម ឬបទល្មើសអកម្មនោះត្រូវតែបានធ្វើឡើងដោយចេតនា។ និង (៣) បទល្មើសសកម្ម ឬបទល្មើសអកម្មនោះត្រូវតែបានធ្វើឡើងដោយមានគោលបំណងជាក់លាក់ណាមួយ ដូចជា ដើម្បីឲ្យបានព័ត៌មាន ឬ "ចម្លើយសារភាព" ដើម្បីដាក់ទណ្ឌកម្ម បំភិតបំភ័យឬបង្ខិតបង្ខំជនរងគ្រោះឬតតីយជន ឬដើម្បីរើសអើងដោយមូលហេតុណាមួយប្រឆាំងនឹងជនរងគ្រោះឬតតីយជន[48]។ ការធ្វើទារុណកម្ម[49] គឺមិនចាំបាច់តម្រូវឲ្យមានការរង

---

[45] សាលដីកា *Kunarac* កថាខ័ណ្ឌ១១៦។

[46] *វេទ្ធអាជ្ញា ទល់នឹង Kunarac, Kovac and Vukovic* សាលក្រមៈច្បាប់ជាធរមាន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី(ICTY) សំណុំរឿងលេខ. IT-96-23-T ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០០១ កថាខ័ណ្ឌ ៥៤២ ("សាលក្រម *Kunarac*")។

[47] សាលដីកា *Kunarac* កថាខ័ណ្ឌ១១៩។ សាលក្រម *Kunarac* កថាខ័ណ្ឌ៥៤៣។

[48] សាលក្រម *Limaj* កថាខ័ណ្ឌ២៣៥។ សាលដីកា *Kunarac* កថាខ័ណ្ឌ១៤២-១៤៤។ សាលក្រម *Kunarac* កថាខ័ណ្ឌ ៤៩៧។ *សូមមើល* សាលក្រម *Brdjanin* កថាខ័ណ្ឌ៤៨១។ សាលក្រម *Krnojelac* កថាខ័ណ្ឌ១៧៩។

របួសជាអចិន្ត្រៃយ៍នោះទេឬក៏មិនតម្រូវឱ្យកំរិតនៃការឈឺចាប់នោះត្រូវតែបានធ្វើឡើងដោយៈ ទារុណកម្មនោះដែរគឺអាស្រ័យទៅលើករណីនីមួយៗ[50]។ លើសពីនេះមិនចាំបាច់តម្រូវឱ្យចារីធ្វើអំពើដែលក្នុងតួនាទីជាផ្លូវការនោះទេ[51]។

២១. យុត្តិសាស្ត្រដែលទាក់ទងជាក់លាក់ទៅនឹងមណ្ឌលឃុំឃាំងនានា បានរកឃើញថា ស្ថានភាពនៃការឃុំឃាំង កង្វះខាតការព្យាបាល និងការរំលោភបំពានដោយផ្ទួនៗ និងជាលក្ខណៈប្រព័ន្ធទៅលើអ្នកជាប់ឃុំឃាំងគឺសុទ្ធតែជាសញ្ញាដែលបង្ហាញឱ្យឃើញអំពីការធ្វើទារុណកម្ម[52]។ ការរំលោភបំពានហួសហេតុក្នុងអំឡុងពេលសួរចម្លើយរួមគ្នាជាមួយចេតនាដើម្បីស្រង់ឱ្យបាន“ចម្លើយសារភាព” ឬព័ត៌មាន ក៏ចាត់ទុកថាជាការធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ[53]។ តាមច្បាប់អន្តរជាតិ ប្រធានពន្ធនាគារ គឺជាអ្នកទទួលខុសត្រូវក្នុងការការពារអ្នកទោសកុំឱ្យមានការរំលោភបំពានដោយខុសច្បាប់ និងដើម្បីធានាឱ្យស្ថានភាពរស់នៅបានប្រកបដោយភាពមនុស្សធម៌។ ប្រធានពន្ធនាគារទាំងឡាយណាដែលធ្វើបាបអ្នកទោសដោយខ្លួនឯងផ្ទាល់ដើម្បីធ្វើជាគំរូដល់អ្នកក្រោមបង្គាប់របស់ខ្លួន ដែលរួមចំណែកបង្កឱ្យមាន“បរិយាកាសនិទណ្ឌភាព”ហេតុនេះអាចត្រូវទទួលខុសត្រូវជាបទព្រហ្មទណ្ឌ[54] ។

## ៥. ការធ្វើមនុស្សឃាត

២២. ការធ្វើមនុស្សឃាត ដែលចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺតម្រូវឱ្យមានធាតុផ្សំចំនួនបី(៣): (១) ការស្លាប់របស់ជនរងគ្រោះ (២) ការស្លាប់នោះគឺបណ្តាលមកពីការប្រព្រឹត្តិបទល្មើសសកម្ម

---

[49] សាលក្រម *Brdjanin* កថាខ័ណ្ឌ៤៨៤។

[50] សាលក្រម *Brdjanin* កថាខ័ណ្ឌ៤៨៣។

[51] សាលដីកា *Kunarac* កថាខ័ណ្ឌ១៤៨។

[52] សាលក្រម *Kvocka* កថាខ័ណ្ឌ១៥១។

[53] សាលក្រម *Krnojelac* កថាខ័ណ្ឌ២៥៥។

[54] *រដ្ឋអាជ្ញា ទល់នឹង* Dragan Nikolic, សាលក្រមផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី(ICTY) សំណុំរឿងលេខIT-94-2-S ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ កថាខ័ណ្ឌ១៧៩ (“សាលក្រមផ្តន្ទាទោស *Nikolic*”)។

និងបទល្មើសអកម្មរបស់ជនជាប់ចោទ ឬរបស់ជនណាម្នាក់ឬច្រើននាក់ផ្សេងទៀត ដែលការប្រព្រឹត្តិបទល្មើសសកម្ម និងបទល្មើសអកម្មរបស់ជនផ្សេងទៀតនោះ គឺជនជាប់ចោទជាអ្នកត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ និង (៣) បទល្មើសសកម្ម ឬបទល្មើសអកម្មត្រូវបានប្រព្រឹត្តដោយជនជាប់ចោទ ឬដោយជនណាម្នាក់ឬច្រើននាក់ផ្សេងទៀត ដែលបទល្មើសសកម្ម ឬបទល្មើសអកម្ម ទាំងនោះត្រូវបានជនជាប់ចោទជាអ្នកត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដោយមានចេតនាសម្លាប់ ឬបង្កឱ្យមានការខូចខាតលើរាងកាយធ្ងន់ធ្ងរ ឬធ្វើឱ្យរងរបួសជាទម្ងន់ ដោយមានហេតុផលដឹងថា បទល្មើសសកម្ម ឬបទល្មើសអកម្មនេះ គឺប្រាកដជានឹងបណ្តាលឱ្យមានការស្លាប់បាត់បង់ជីវិតជាពុំខាន[55]។ មិនចាំបាច់តម្រូវឱ្យបង្ហាញសាកសពជនរងគ្រោះដើម្បីធ្វើជាភស្តុតាងនៃការស្លាប់នោះទេ[56]។

## ៦. ការសម្លាប់រង្គាល

២៣. ការសម្លាប់រង្គាល ដែលចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាំបាច់តម្រូវមានធាតុផ្សំចំនួនពីរដើម្បីចង្អុលបង្ហាញអំពីបទល្មើសនេះ : (១) បទល្មើសសកម្ម ឬបទល្មើសអកម្ម បណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ និង (២) ជនជាប់ចោទមានចេតនាដើម្បីសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬដើម្បីបង្កើតឡើងនូវស្ថានភាពរស់នៅដែលបណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ[57]។ ការសម្លាប់ក្នុងទ្រង់ទ្រាយធំអាចត្រូវបានបង្ហាញឱ្យឃើញតាមភស្តុតាងថា បានកើតឡើងដោយសារការដាក់មនុស្សឱ្យរស់នៅក្នុងស្ថានភាពដែលរួមចំណែក ក្នុងការធ្វើឱ្យពួកគេត្រូវស្លាប់បាត់បង់ជីវិត ដូចជាការបង្អត់អាហារនិងការព្យាបាលសុខភាព ដែលសំដៅធ្វើឱ្យមានការបំផ្លិចបំផ្លាញប្រជាជនមួយផ្នែក[58]។ មិនមានតម្រូវការចាំបាច់ឱ្យផ្តល់ពីចំនួនអប្បបរមានៃជនរងគ្រោះ ដើម្បីបំពេញឱ្យគ្រប់គ្រាន់តាមលក្ខខណ្ឌដែលតម្រូវថា ទំហំនៃការស្លាប់នោះមាន "ទ្រង់ទ្រាយធំ" នោះទេ។

---

[55] សាលក្រម *Brdjanin* កថាខ័ណ្ឌ៣៨១។

[56] សាលក្រម *Brdjanin* កថាខ័ណ្ឌ៣៨៣។ សាលក្រម *Krnojelac* កថាខ័ណ្ឌ៣២៦។

[57] សាលក្រម *Blagojevic* កថាខ័ណ្ឌ៥៧២។ សាលក្រម *Brdjanin* កថាខ័ណ្ឌ៣៨៨។

[58] សាលក្រម *Brdjanin* កថាខ័ណ្ឌ៣៨៩។ *សូមមើលផងដែរ ទល់នឹង* *Radislav Krstic* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី(ICTY) សំណុំរឿងលេខ IT-98-33-T ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខ័ណ្ឌ៥០៣ ("សាលក្រម *Krstic*")។

ហើយបញ្ហានេះអាចត្រូវបានវាយតម្លៃដោយផ្អែកទៅតាមករណីនីមួយៗ អាស្រ័យទៅលើការប្រព្រឹត្តបទឧក្រិដ្ឋ ដែលបានដាក់បន្ទុករួចហើយ និងកត្តាទាំងអស់ដែលពាក់ព័ន្ធ[59]។

## ៧. ការធ្វើទុក្ខបុកម្នេញ

២៤. ការធ្វើទុក្ខបុកម្នេញគឺជាឧក្រិដ្ឋកម្មមួយ ដែលត្រូវបានគេផ្តល់និយមន័យថាគឺជាការរើសអើង ដោយហេតុផលខាង នយោបាយ ពូជសាសន៍ និងសាសនា ហើយដែលចាំបាច់ត្រូវមានធាតុផ្សំចំនួនពីរ (២) ដើម្បីចង្អុលបង្ហាញអំពីបទល្មើសនេះ: (១) បទល្មើសសកម្ម ឬបទល្មើសអកម្មនាំឱ្យមានអង្គហេតុនៃការរើសអើងហើយដែលមានការបដិសេធ ឬការបំពារបំពានទៅលើសិទ្ធិជាមូលដ្ឋាន ដូចមានចែងក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិ ឬ ច្បាប់សន្ធិសញ្ញា និង (២) បទល្មើសសកម្ម ឬបទល្មើសអកម្មដែលបានប្រព្រឹត្តឡើងដោយចេតនាក្នុងគោលបំណងដើម្បីឱ្យមានការរើសអើង ដោយសារមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនដូចដែលបានលើកឡើងរួចមកហើយ[60]។ ទង្វើតែមួយគត់ប៉ុណ្ណោះក៏អាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់កំណត់ថាជាការធ្វើទុក្ខបុកម្នេញបានដែរ ដរាបណាបានបង្ហាញ

---

[59] សាលក្រម *Blagojevic* កថាខ័ណ្ឌ៥៧៣។ សាលក្រម *Brdjanin* កថាខ័ណ្ឌ៣៩១។ សាលក្រម *Stakic* កថាខ័ណ្ឌ៦៤០។ *រដ្ឋអាជ្ញា ទល់នឹង Krajisnik* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្ម អន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) សំណុំរឿងលេខ IT-00-39-T ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខ័ណ្ឌ៧១៦ (សាលាក្រម *Krajisnik*)។

[60] សាលដីកា *Deronjic* កថាខ័ណ្ឌ១០៩។ *សូមមើល រដ្ឋអាជ្ញា ទល់នឹង Miroslav Kvocka Mlado Radic Zoran Zigic & Dragoljub Prcac* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្ម អន្តរជាតិសម្រាប់ អតីតយូហ្គោស្លាវី(ICTY) សំណុំរឿងលេខ IT-98-30/1-A ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខ័ណ្ឌ៣២០, ៤៥៥ ("សាលដីកា *Kvocka*")។ សាលដីកា *Kordic* កថាខ័ណ្ឌ១០១។ សាលដីកា *Blaskic* កថាខ័ណ្ឌ១៣១។ សាលដីកា *Vasiljevic* កថាខ័ណ្ឌ១១៣។ *រដ្ឋអាជ្ញា ទល់នឹង Milorad Krnojelac* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) សំណុំរឿងលេខ IT-97-25-A ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខ័ណ្ឌ១៨៥ ("សាលដីកា *Krnojelac*")។ សាលក្រម *Blagojevic* កថាខ័ណ្ឌ៥៧៩។ សាលក្រម *Brdjanin* កថាខ័ណ្ឌ៩៩២។ សាលក្រម *Simic* កថាខ័ណ្ឌ៤៧។

ភស្តុតាងអំពីមានធាតុផ្សំទាំងពីរខាងលើ[61] តែអំពើនៃការធ្វើទុក្ខបុកម្នេញជាក់លាក់ណាមួយត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់[62]។

២៥. អំពើនៃការធ្វើទុក្ខបុកម្នេញរួមមាន អំពើនានាដែលមានស្ថានទម្ងន់ប្រហែលនឹងអំពើទាំងឡាយ ដូចដែលបានរៀបរាប់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[63] ដែលក្នុងនោះរួមមាន អំពើឃាតកម្ម ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម។ ការធ្វើឱ្យអាម៉ាស់អាចចាត់ទុកជាការធ្វើទុក្ខបុកម្នេញដែរ[64] ហើយការដែលបង្ខំឱ្យទៅធ្វើជាសាក្សីដើម្បីឱ្យឃើញ ឬស្តាប់ការធ្វើទារុណកម្ម ការស្លូវចម្លើយ និងការប្រព្រឹត្តិអំពើឃោរឃៅគ្មានគោលបំណងនៅក្នុងមន្ទីរឃុំឃាំងត្រូវបានរកឃើញថាគឺសុទ្ធតែជាការរំលោភបំពានខាងស្មារតី និងជាទម្រង់មួយនៃការធ្វើទុក្ខបុកម្នេញ[651]។ ការដាក់ក្នុងមន្ទីរឃុំឃាំងដែលចេះតែពន្យារពេលយូរ ក៏អាចក្លាយទៅជាការធ្វើទុក្ខបុកម្នេញដែរ ប្រសិនបើទង្វើនេះត្រូវបានអនុវត្តដោយមានចេតនារើសអើង យ៉ាងច្បាស់ថាដោយមកពីហេតុផលខាងសាសនា នយោបាយ ឬពូជសាសន៍[66]។ ការវាយដំ ឬធ្វើទារុណកម្មដោយសារការជាប់ទាក់ទងខាងនយោបាយ ឬសាសនារបស់ជនរងគ្រោះ ក៏ជាការបង្ហាញឱ្យឃើញអំពី

---

[61] សាលដីកា *Kordic* កថាខ័ណ្ឌ១០២។ សាលដីកា *Blaskic* កថាខ័ណ្ឌ១៣៥។ សាលដីកា *Vasiljevic* កថាខ័ណ្ឌ១១៣។ សាលក្រម *Blagojevic* កថាខ័ណ្ឌ៥៨២។

[62] សាលដីកា *Blaskic* កថាខ័ណ្ឌ១៣៩។

[63] សាលដីកា *Kordic* កថាខ័ណ្ឌ១០២និង៦៧១។ *សូមមើល* សាលដីកា *Kvocka* កថាខ័ណ្ឌ៣២១។ សាលដីកា *Blaskic* កថាខ័ណ្ឌ១៣៥។

[64] ការធ្វើឱ្យអាម៉ាស បានត្រូវកំណត់និយមន័យថាជាអំពើដែលបង្កឱ្យមានការខូចខាតផ្លូវចិត្ត រាប់បញ្ចូលទាំងការដាក់អ្នកទោសនៅក្នុងកន្លែងតូចចង្អៀត និងកខ្វក់ ការធ្វើឱ្យពួកគេសុំទឹកផឹក ហើយនិងការដាក់ពួកគេឱ្យស្ថិតនៅក្រោម ការវាយដំ ការគម្រាមកំហែង និងការធ្វើឱ្យបាក់ស្មារតីជាប្រចាំ ។ សាលក្រម *Kvocka* កថាខ័ណ្ឌ១៩០។ សាលដីកា *Kvocka* កថាខ័ណ្ឌ៣២៤-៣២៥។ សាលក្រមផ្តន្ទាទោស *Nikolic* កថាខ័ណ្ឌ៦៩។

[65] សាលក្រម *Kvocka* កថាខ័ណ្ឌ១៩២។

[66] សាលក្រម *Krnojelac* កថាខ័ណ្ឌ៤៣៨។

00364858

E1/53



ចេតនារើសអើងដែលលក្ខខណ្ឌបានតម្រូវដែរ[67]។ ចេតនារើសអើងដែលបានតម្រូវនោះក៏អាចទាញជាសេចក្តីសន្និដ្ឋានបានតាមរយៈលក្ខណៈរើសអើងរបស់មណ្ឌលឃុំឃាំងនោះទាំងមូលតែម្តង[68]។

## អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនៅលើអនុសញ្ញាទីក្រុងហ្សឺណែវ

២៦. មាត្រា៦ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តល់សិទ្ធិអំណាចដល់ អ.វ.ត.ក ដើម្បីនាំខ្លួនបុគ្គលជនសង្ស័យទាំងអស់ពីបទប្រព្រឹត្តអំពើបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ (អំពើបំពារបំពានធ្ងន់ធ្ងរ) មកកាត់ទោស។ បទល្មើស ជាក់លាក់មួយចំនួនដូចមានចែងនៅក្នុងមាត្រា៦ រួមមាន អំពើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្តីដោយត្រឹមត្រូវយុត្តិធម៌ និងដោយទៀងទាត់ និងការបង្ខាំងជនស៊ីវិលដោយខុសច្បាប់។ ដូចគ្នានេះដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(ICTY)[69] និងតុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC)[70] មានអំណាចកាត់ទោសលើឧក្រិដ្ឋកម្មដូចគ្នានេះ ដូចដែលមានចែងក្នុងមាត្រា ៦ ពោលគឺ លើការបង្ខាំងជនស៊ីវិលដោយខុសច្បាប់[71] ការដកហូតសិទ្ធទទួលបានការកាត់ទោសដោយត្រឹមត្រូវយុត្តិធម៌ និងដោយទៀងទាត់[72] ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព[73]

---

[67] សាលដីកា *Kvocka* កថាខ័ណ្ឌ៣៦៦។

[68] សាលដីកា *Kvocka* កថាខ័ណ្ឌ៣៦៤និង៣៦៦។

[69] ច្បាប់លក្ខន្តិកៈ តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា២។

[70] ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៨។

[71] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា២(ច)។ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២ (ក)(vii)។

[72] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា ២(ង)។ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២(ក)(vi)។

[73] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា២ (គ) ។ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមមា ត្រា២ (ក)(iii)។

ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌[74] និងអំពើមនុស្សឃាតដោយចេតនា[75]។ ធាតុផ្សំនៃបទល្មើសទាំងនេះត្រូវបានពិភាក្សាដូចខាងក្រោមនេះ ។

២៧. ចំពោះការប្រព្រឹត្តិបទល្មើស ដែលបង្កឲ្យមានអំពើបំពារបំពានធ្ងន់ធ្ងរ ធាតុផ្សំនៃយុត្តាធិការមួយចំនួនបានតម្រូវឲ្យមានចាំបាច់: (១) បទល្មើសជាក់លាក់ត្រូវតែប្រព្រឹត្តិក្នុងបរិបទនៃ/និងរួមបញ្ចូលគ្នាជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិ (២) ចារីបានដឹងអំពីស្ថានភាពជាក់ស្តែង ដែលបានបង្កើតឱ្យមានជម្លោះប្រដាប់អាវុធ (៣) អំពើ ត្រូវបានប្រព្រឹត្តិប្រឆាំងមនុស្សជាតិ ឬទ្រព្យសម្បត្តិ ដែលត្រូវបានការពារដូចមានចែងក្នុងអនុសញ្ញាក្រុងហ្សឺណែវមួយឬច្រើន ក្នុងឆ្នាំ១៩៤៩ និង (៤) ចារីបានដឹងស្ថានភាព ដែលបង្កើតបានជាឋានៈ ដែលត្រូវការពារនេះ[76] ។

## លក្ខខណ្ឌតម្រូវនៃយុត្តាធិការ

## ១. ជម្លោះប្រដាប់អាវុធអន្តរជាតិ

២៨. ជម្លោះប្រដាប់អាវុធអន្តរជាតិត្រូវតែកើតមានដោយពិតប្រាកដ។ លើសពីនេះទៀត ត្រូវមានចំណងទាក់ទងគ្នាមួយរវាងជម្លោះអន្តរជាតិ និងឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់[77]។ ជម្លោះប្រដាប់អាវុធកើតមាន "នៅពេលណាមានដំណោះស្រាយដោយការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធរវាងរដ្ឋ

[74] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី, មាត្រា 2(b)។ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា 2(ក)(ii)។

[75] ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា 2(ក)។ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា 2(ក) (i)។

[76] គណៈកម្មការរៀបចំតុលាការព្រហ្មទណ្ឌអន្តរជាតិ PCNICC/2000/L.1/Rev.1/Add.2 (២០០០) ឧបសម្ព័ន្ធ III។ សូមមើលសៀវភៅនិពន្ធដោយ Knut DORMANN ចូលរួមវិភាគទានដោយ Louise DOSWALD-BECK និង Robert KOLB មានចំណងជើងថា ធាតុផ្សំនៃក្រិដ្ឋកម្មសង្គ្រាមដែលស្ថិតនៅក្រោមលក្ខន្តិកៈក្រុងរ៉ូមនៃតុលាការ ព្រហ្មទណ្ឌអន្តរជាតិ៖ ប្រភពនិងសេចក្តីអត្ថាធិប្បាយ (*Elements of War Crimes under the Rome Statute of the International Criminal Court: Sources and Commentary)* (Cambridge University Press, 2002) ទំព័រ១៧។

[77] *រដ្ឋអាជ្ញាទល់នឹង Sefer Halilovic* សាលក្រមបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) សំណុំរឿងលេខ. IT-01-48-T ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥ កថាខ័ណ្ឌ២៩ (សាលក្រម *Halilovic*)។ សាលក្រម *Brdjanin* កថាខ័ណ្ឌ ១២៨។

នានាឬដោយអំពើហិង្សាប្រដាប់អាវុធយូរអង្វែងរវាងអាជ្ញាធរនៃរដ្ឋាភិបាល និងក្រុមប្រដាប់អាវុធដែលមានការចាត់តាំង ឬរវាងក្រុមទាំងនេះនៅក្នុងរដ្ឋណាមួយ[78]។ ជម្លោះប្រដាប់អាវុធមួយអាចក្លាយទៅជាជម្លោះប្រដាប់អាវុធអន្តរជាតិ នៅពេលជម្លោះទាំងនេះមានការចូលរួមដោយរដ្ឋពីរ ឬច្រើន។ លក្ខខណ្ឌតម្រូវពីទំនាក់ទំនងគ្នារវាងជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ត្រូវបានបំពេញគ្រប់គ្រាន់គឺ នៅពេលដែល ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងនោះមាន "*ទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ*" ទៅនឹងអំពើអរិភាពនានា។ មិនចាំបាច់តម្រូវឱ្យបង្ហាញភស្តុតាងថា ឧក្រិដ្ឋកម្មទាំងនោះ ត្រូវបានប្រព្រឹត្តនៅក្នុងតំបន់តែមួយជាមួយគ្នានិងសកម្មភាពវាយប្រយុទ្ធគ្នាជាក់ស្តែងនោះទេ[79]។

## ២. ជនដែលត្រូវទទួលបានការការពារ

២៩. អនុសញ្ញាក្រុងហ្សឺណែវទី IV បានពង្រីកបន្ថែមនូវឋានៈនៃ "ជនដែលត្រូវទទួលបានការការពារ" ដល់ជនស៊ីវិលនៃរដ្ឋដែលកំពុងប្រយុទ្ធគ្នាណាមួយដែល "ស្ថិតក្នុងកណ្តាប់ដៃនៃភាគីជម្លោះ ឬភាគីដែលមានអំណាចក្តោបក្តាប់ណាមួយ ដែលខ្លួនមិនមែនជាជាតិសាសន៍របស់ភាគីនោះ"[80]។ អនុសញ្ញានេះការពារ ជនស៊ីវិលដែលរសាត់ខ្លួនចូលក្នុងទឹកដីដែលត្រួតត្រាដោយរដ្ឋជាបច្ចាមិត្រ[81]។ តាមធម្មតាឋានៈជនដែលត្រូវទទួលការការពារនេះគឺគេកំណត់តាមរយៈសញ្ជាតិ ប៉ុន្តែគេអាចកំណត់វាបានដែរតាមរយៈការ ធ្វើតេស្តរក "ស្វាមីភក្តិ" ពោលគឺផ្តោតលើស្វាមីភក្តិរបស់ជននោះចំពោះភាគីណាមួយ

[78] *រដ្ឋអាជ្ញា ទល់នឹង Dusko Tadic* សាលដីកាលើបណ្តឹងរបស់មេធាវីការពារក្តីចំពោះបណ្តឹងឧទ្ធរណ៍លើ បញ្ហា យុត្តាធិការ IT-94-1-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ៧០។

[79] អង្គជំនុំជម្រះសាលាដំបូង *Vasiljevic* កថាខណ្ឌ២៥។

[80] អនុសញ្ញាទីក្រុងហ្សឺណែវ (IV) ទាក់ទិននឹងការការពារជនស៊ីវិល ក្នុងអំឡុងពេលមានសង្គ្រាម ថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩ មាត្រា៤ (1) ("អនុសញ្ញាទីក្រុងហ្សឺណែវ IV")។ អនុសញ្ញានេះចាប់ផ្តើមតាមរយៈការការពារមនុស្សគ្រប់រូប ដែលស្ថិត"នៅក្នុងដៃភាគីណាមួយនៃពីជម្លោះ ឬភាគីដែលគ្រប់គ្រងអំណាចដែលខ្លួនមិនមែនជាសញ្ជាតិនោះ"។ សន្ធិសញ្ញានេះមិនរាប់បញ្ចូលនូវជនជាតិណាដែលមកពីរដ្ឋអព្យាក្រឹត្យ ឬរដ្ឋដែលមានសង្គ្រាម អ្នកទាំងឡាយណាដែល សុំការការពារក្រោមសន្ធិសញ្ញាណាមួយនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងក្រុមផ្សេងៗទៀតដែលមានឋានៈត្រូវទទួល បានការការពារ។ អ្នកទាំងឡាយណាដែលបានរាប់បញ្ចូលគឺមានឋានៈដែលត្រូវទទួលបានការការពារ។ ក្នុងការ អនុវត្តន៍ ក្រុមដែលមានសិទ្ធិទទួលបានការការពារគឺជនស៊ីវិលនៃរដ្ឋដែលជាសត្រូវ។

[81] សាលក្រម *Naletilic* កថាខណ្ឌ២០៨។

នៃជម្លោះប្រដាប់អាវុធជាជាងការកំណត់ទៅលើតែសញ្ជាតិរបស់ពួកគាត់[82]។ ឋានៈដែលត្រូវទទួលបានការការពារនេះអាចអនុវត្តបានដែរចំពោះបុគ្គលទាំងឡាយណា ដែលមានសញ្ជាតិដូចគ្នានឹងអ្នកដែលចាប់គាត់ ត្បិតនៅក្នុងជម្លោះសម័យទំនើប គេអាច "ដាក់បញ្ចូល" ជនរងគ្រោះថាជាមនុស្សរបស់រដ្ឋបដិបក្ខក្នុងជម្លោះប្រដាប់អាវុធនោះ បើទោះបីការពិត ពួកគាត់មានសញ្ជាតិជាផ្លូវការដូចគ្នានឹងអ្នកចាប់ពួកគាត់យ៉ាងណាក៏ដោយ[83]។ អនុសញ្ញាក្រុងហ្សឺណែវទី III ក្តោបការការពារនេះរហូតដល់ "សមាជិកកងកម្លាំងប្រដាប់អាវុធនៃភាគីណាមួយក្នុងជម្លោះ" ដែលបាន "ធ្លាក់ចូលក្នុងអំណាចរបស់បច្ចាមិត្រ"[84]។ តាមធម្មតាគេចាត់ទុកជន ដែលត្រូវទទួលបានការការពារប្រភេទនេះថាជា "ឈ្លើយសឹក"។

## ៣. ការដឹងឮអំពីកាលៈទេសៈពិតជាក់ស្តែង

៣០. បន្ថែមលើការមាន *ចេតនាឧក្រិដ្ឋ* ដែលជាលក្ខខណ្ឌចំបាច់ចំពោះបទឧក្រិដ្ឋជាក់លាក់ណាមួយនោះ ចារីត្រូវតែ: (១) ដឹងអំពីកាលៈទេសៈពិតជាក់ស្តែងនៃអត្ថិភាពនៃជម្លោះប្រដាប់អាវុធ និង (២) ដឹងអំពីកាលៈទេសៈពិតជាក់ស្តែង ដែលបង្កើតបានជាឋានៈដែលត្រូវទទួលបានការការពារ។ ការដឹងថារដ្ឋបរទេសណាមួយ មានជាប់ពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ គឺជាការបំពេញនូវធាតុផ្សំទី១ស្តីអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ[85]។ ការដឹងថាជនរងគ្រោះជាជននៃភាគីបដិបក្ខនៅក្នុងជម្លោះ គឺបំពេញធាតុផ្សំទី២ ស្តីពី ឋានៈរបស់ជនរងគ្រោះ[86]។

---

[82] សាលដីកា *Kordic* កថាខ័ណ្ឌ៣២២-៣២៣ ៣២៨-៣៣០។

[83] សាលដីកា *Blaskic* កថាខ័ណ្ឌ១៧៤ សាលដីកា *Kordic* កថាខ័ណ្ឌ៣២៩-៣៣០។ សូមមើល សាលដីកា រវាង*រដ្ឋអាជ្ញា ទល់នឹង Dusko Tadic* របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-94-1-A ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខ័ណ្ឌ១៦៦ (សាលដីការបស់ Tadic)។

[84] អនុសញ្ញាទីក្រុងហ្សឺណែវ (III) ទាក់ទិននឹងប្រព្រឹត្តកម្មលើឈ្លើយសឹក ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ មាត្រា៤ ("អនុសញ្ញាទីក្រុងហ្សឺណែវ III")។

[85] សាលដីកា *Kordic* កថាខ័ណ្ឌ៣១១។

[86] សៀវភៅនិពន្ធដោយ Knut DORMANN ចូលរួមវិភាគទានដោយ Louise DOSWALD-BECK និង Robert KOLB មានចំណងជើងថា *ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមលក្ខន្តិកៈក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌ អន្តរជាតិ: ប្រភពសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីច្បាប់សារធាតុជាធរមាន ស្របតាមវិធាន៩២*

## បទល្មើសជាក់លាក់

### ១. ការបង្ខាំងប្រជាជនស៊ីវិលដោយខុសច្បាប់

៣១. ធាតុផ្សំនៃការបង្ខាំងដោយខុសច្បាប់ គឺដូចគ្នាបេះបិទនឹងធាតុផ្សំនៃការដាក់ក្នុងមន្ទីរឃុំឃាំងមនុស្ស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ[87]។

### ២. អំពើដកហូតសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ និងទៀងទាត់

៣២. ការដកហូតសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ និងប្រក្រតី ពីជនដែលត្រូវទទួលបានការការពារ ដោយការបដិសេធចោលនូវការធានាតាមផ្លូវតុលាការដូចមានចែងជាពិសេសក្នុងអនុសញ្ញានៃទីក្រុងហ្សឺណែវទីIII ឆ្នាំ១៩៤៩ គឺការបំពារបំពានយ៉ាងធ្ងន់ធ្ងរចំពោះអនុសញ្ញានៃទីក្រុងហ្សឺណែវ។ សិទ្ធិទាំងឡាយដូចតទៅនេះគឺមិនអាចត្រូវបដិសេធចោលបានឡើយ: (១) សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការវិនិច្ឆ័យក្តីដោយតុលាការមួយឯករាជ្យ និងអនាគតិ[88] (២) សិទ្ធិត្រូវទទួលការជូនដំណឹងឲ្យដឹងភ្លាមៗ អំពីបទល្មើសដែលជនជាប់ចោទត្រូវបានគេចោទប្រកាន់[89] (៣) ការការពារកុំឲ្យមានធ្វើការផ្តន្ទាទោសជាសមូហភាព[90] (៤) សិទ្ធិទទួលបានការការពារទៅតាមគោលការណ៍នីត្យានុកូលភាព[91] (៥) សិទ្ធិមិនត្រូវបានគេផ្តន្ទាទោសលើសពីមួយដងចំពោះ បទការប្រព្រឹត្តដដែល ឬបទចោទតែមួយ (*ne bis in idem*)[92] (៦) សិទ្ធិទទួលបានការជូនដំណឹង អំពីសិទ្ធិប្តឹង

*និងការអត្ថាធិប្បាយ Elements of War Crimes under the Rome Statute of the International Criminal Court: Sources and Commentary* (Cambridge University Press, 2002) ទំព័រ២៩។

[87] សាលក្រម Kordic កថាខ័ណ្ឌ២៩២។ សាលក្រម *Simic* កថាខ័ណ្ឌ៦៣។

[88] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៨៤ (២)។

[89] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១០៤ ។ អនុសញ្ញាទីក្រុងហ្សឺណែវ IV, មាត្រា៧១ (២)។

[90] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៨៧ ។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៣៣។

[91] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៩៩ (១) ។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៦៧។

[92] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៨៦ ។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា 117(៣)។

ឧទ្ទរណ៍[93] (៧) សិទ្ធិមិនត្រូវបានគេកាត់ទោស ឬប្រហារជីវិត ដោយគ្មានការប្រកាសសាលក្រមជាមុន ដោយតុលាការ ដែលបានបង្កើតត្រឹមត្រូវតាមផ្លូវច្បាប់[94]។

## ៣. ចេតនាធ្វើឱ្យរងការឈឺចាប់ដ៏ធំធេង ឬឱ្យមានរបួសស្នាមធ្ងន់ធ្ងរដល់រូបរាងកាយ ឬដល់សុខភាព

៣៣. ឧក្រិដ្ឋកម្មនេះត្រូវបានគេឱ្យនិយមន័យថា ជាអំពើឬការខកខានមិនបានធ្វើអំពើដោយចេតនាមួយដែលបង្កឱ្យមានការរងទុក្ខវេទនាដ៏ធំធេងដល់ផ្លូវចិត្ត ឬដល់រូបរាងកាយ ឬការរងរបួស[95]។ ប្រភេទនៃឧក្រិដ្ឋកម្មទាំងនេះ រួមបញ្ចូលនូវអំពើមួយចំនួនដែលបំពេញមិនបានគ្រប់ទៅតាមលក្ខខណ្ឌតម្រូវនៃអំពើទារុណកម្មផងដែរ ដែលទោះបីជារាល់អំពើនៃការធ្វើទារុណកម្មទាំងអស់អាចស្ថិតនៅក្នុងរង្វង់នៃបទល្មើសមួយនេះយ៉ាងណាក៏ដោយ[96]។ បើទោះបីជាជនរងគ្រោះត្រូវតែទទួលរងទុក្ខទោស"ដ៏ធ្ងន់ធ្ងរ" យ៉ាងណាក្តី ក៏មិនចាំបាច់តម្រូវរកភស្តុតាងឱ្យឃើញថា ការរងរបួសមួយ ឬច្រើនទាំងនោះ គឺជាការរងទុក្ខវេទនាជាអចិន្ត្រៃយ៍ ឬដែលមិនអាចជួសជុលវិញបាននោះដែរ[97]។ ឧក្រិដ្ឋកម្មមួយនេះមានលក្ខណៈខុសគ្នាពីឧក្រិដ្ឋកម្មនៃប្រព្រឹត្តកម្មអមនុស្សធម៌ ដែលតម្រូវឱ្យមានការបង្ហាញភស្តុតាងអំពីការរងរបួសធ្ងន់ធ្ងរដល់រូបរាងកាយ និងផ្លូវចិត្ត។ ការធ្វើឱ្យខូចខាតដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាបុគ្គល គឺមិនរាប់បញ្ចូលនៅក្នុងបទល្មើស នេះទេ[98]។

---

[93] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា១០៦ ។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៧៣។

[94] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា៣ ។ អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា៣។

[95] សាលក្រម *រដ្ឋអាជ្ញា* ទល់នឹង *Kordic និង Cerkez* តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-94-14/2-T ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខ័ណ្ឌ២៤៥ (សាលក្រម *Kordic)។* សាលក្រម *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaskic* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-95-14-T ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខ័ណ្ឌ១៥៦ ("សាលក្រម *Blaskic*")។ សាលក្រម *រដ្ឋអាជ្ញា ទល់នឹង Zejnil Delalic Zdravko Mucic* aka "*Pavo*" *Hazim Delic and Esad Landzo* aka "Zenga" *Delalic* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ. IT-96-21-T ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខ័ណ្ឌ៥១១ ("សាលក្រម *Delalic*")។

[96] សាលក្រម *Delalic* កថាខ័ណ្ឌ៥១១ សាលក្រម *Blaskic* កថាខ័ណ្ឌ១៥៦។

[97] សាលក្រម *Naletilic* កថាខ័ណ្ឌ៣៤០-៣៤១ សាលក្រម *Kordic* កថាខ័ណ្ឌ២៤៥។

[98] សាលក្រម *Kordic and Cerkez* កថាខ័ណ្ឌ២៤៥។

## ៤. ការធ្វើទារុណកម្ម ឬប្រព្រឹត្តិកម្មអមនុស្សធម៌

*ការធ្វើទារុណកម្ម*

៣៤. ធាតុផ្សំទាំងឡាយនៃអំពើទារុណកម្ម ដែលចាត់ទុកថាជា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរចំពោះអនុសញ្ញានៃទីក្រុងហ្សឺណែវ គឺដូចគ្នាបេះបិទនឹងធាតុផ្សំនៃអំពើទារុណកម្មដែលចាត់ទុកថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ[99]។

*ប្រព្រឹត្តកម្មអមនុស្សធម៌*

៣៥. ប្រព្រឹត្តកម្មអមនុស្សធម៌ត្រូវបានគេកំណត់និយមន័យថា គឺជា បទល្មើសសកម្ម ឬបទល្មើសអកម្មដោយចេតនាមួយដែលបង្កឱ្យមានការខូចខាតដ៏ធ្ងន់ធ្ងរដល់ស្មារតី ឬការឈឺចាប់ដល់រូបរាងកាយ ឬការរងរបួស ឬចាត់ទុកថាការវាយប្រហារធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនទាំងឡាយដែលត្រូវបានទទួលការការពារ[100]។ រាល់អំពើផ្សេងៗទៀតដែលគេរកឃើញថាជាអំពើទារុណកម្ម ឬដោយមានចេតនាបង្កឱ្យមានការរងឈឺចាប់ដ៏ធំធេង ឬឱ្យមានរបួសស្នាមធ្ងន់ធ្ងរ ក៏ត្រូវបានរាប់បញ្ចូលជាប្រព្រឹត្តកម្មអមនុស្សធម៌ដែរ។ ក៏ប៉ុន្តែប្រភេទនៃបទល្មើសទី៣នេះត្រូវបានពង្រីកបន្ថែមផងដែរ រហូតទៅដល់អំពើផ្សេងៗទៀតដែលរំលោភបំពានទៅលើគោលការណ៍ជាមូលដ្ឋាននៃប្រព្រឹត្តកម្មអមនុស្សធម៌ ជាពិសេសនោះគឺការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស។ បញ្ហាដែលថាតើមានអំពើដោយឡែកណាមួយ ដែលបង្កើតបានជាប្រព្រឹត្តកម្មអមនុស្សធម៌ដែរឬទេនោះ គឺជាបញ្ហាខាងអង្គហេតុ ដែលគេត្រូវយកមកវិនិច្ឆ័យដោយផ្អែកទៅលើរាល់កាលៈទេសៈទាំងអស់ជាមុនសិន[101]។

---

[99] សាលក្រម *Brdjanin* កថាខ័ណ្ឌ៤៨២ "និយមន័យពាក្យថា "ធ្វើទារុណកម្ម" នៅតែដដែល ដោយមិនគិតពីមាត្រា នេះនៃច្បាប់លក្ខន្តិកៈដែលបានចោទទៅលើជនត្រូវចោទឡើយ។"

[100] សាលដីកា *Kordic* កថាខ័ណ្ឌ៣៩ ។ សាលដីកា *Blaskic* កថាខ័ណ្ឌ៦៦៥ ។ សាលក្រម *Kordic* កថាខ័ណ្ឌ២៥៦ *Blaskic* សាលក្រម កថាខ័ណ្ឌ១៥៤-១៥៥ សាលក្រម *Naletilic* កថាខ័ណ្ឌ២៤៦។

[101] សាលក្រម *Delalic* កថាខ័ណ្ឌ៥៤៤។

### ៥. ការធ្វើមនុស្សឃាតដោយចេតនា

៣៦. និយមន័យនៃការធ្វើមនុស្សឃាតដោយចេតនា ដែលចាត់ទុកថាជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរចំពោះអនុសញ្ញានៃទីក្រុងហ្សឺណែវគឺមាននិយមន័យដូចគ្នាបេះបិទទៅនឹងឧក្រិដ្ឋកម្មនៃអំពើឃាតកម្មដែលចាត់ទុកថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(ដូចបានពិពណ៌នាខាងលើ)[102]លើកលែងតែត្រង់ចំណុច ដែលត្រូវបង្ហាញភស្តុតាងថាជនរងគ្រោះនោះពិតជា "ជនដែលត្រូវទទួលបានការការពារ"។

### ឧក្រិដ្ឋកម្មជាតិ

៣៧. **ឌុច** ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើនៃការធ្វើទារុណកម្ម និងអំពើមនុស្សឃាតនៅមន្ទីរ ស-២១ ក្នុងមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ដែលផ្តល់យុត្តាធិការដល់តុលាការនេះទៅលើបទល្មើសទាំងឡាយ ដែលល្មើសនឹងមាត្រា ៥០០, ៥០១, ៥០២, ៥០៤, ៥០៥, ៥០៦, និង ៥០៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។

### ១. ការធ្វើទារុណកម្ម

៣៨. ការធ្វើទារុណកម្ម គឺជាបទល្មើសមួយដែលមានចែងក្នុងមាត្រា៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ អំពើ ទារុណកម្មបានកើតឡើង នៅពេលណាអំពើនៃការធ្វើទារុណកម្មត្រូវបានប្រព្រឹត្ត (១) ក្នុងចេតនាឱ្យបានពត៌មានផ្សេងៗ ដែលមានប្រយោជន៍សម្រាប់ការប្រព្រឹត្តិបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬ (២) ដើម្បីធ្វើការគាបសង្កត់ ឬដោយអំពើព្រៃផ្សៃ។

### ២. ការធ្វើមនុស្សឃាត

[102] សាលដីកា *Kordic* កថាខ័ណ្ឌ៣៨។ *សូមមើលផងដែរ* សាលក្រម *Kordic* កថាខ័ណ្ឌ២២៩ ។ សាលក្រម *Brdjanin* កថាខ័ណ្ឌ ៣៨០ ៣៨១។

៣៩. ការធ្វើមនុស្សឃាត ឬអំពើឃាតកម្មដោយគិតទុកជាមុន គឺជាបទល្មើសមួយ ដែលមានចែងក្នុងមាត្រា៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ អំពើមនុស្សឃាតកើតមានឡើងនៅពេលណាមានការស្លាប់ ដែលបណ្ដាលមកពីអំពើដែលបានប្រព្រឹត្តឡើង ឬដែលបានប៉ុនប៉ងគិតទុកជាមុនដោយមានចេតនាចង់ធ្វើឱ្យស្លាប់។ ប្រសិនបើអំពើមនុស្សឃាតគឺបណ្ដាលមកពីអំពើទាំងឡាយដែលគេធ្វើបានសម្រេច ឬបានរៀបចំធ្វើដោយមានការគិតទុកជាមុន ដោយមានគោលបំណងបង្កឱ្យមានរបួសស្នាម ប៉ុន្តែមិនចង់បណ្ដាលឱ្យស្លាប់ទេនោះ អំពើនោះត្រូវគេកំណត់បទចោទថា ជាអំពើមនុស្សឃាតដោយអចេតនា អនុលោមតាមមាត្រា៥០១ និង៥០៣ នៃក្រមព្រហ្មទណ្ឌ។

## ការទទួលខុសត្រូវ

៤០. មាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក ស្ដីពីការទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មចែងថា ជនសង្ស័យទាំងឡាយណាដែល "បានរៀបចំផែនការញុះញង់ បានបញ្ជា បានជួយជ្រោមជ្រែង ឬបានប្រព្រឹត្ត" ឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលចំពោះឧក្រិដ្ឋកម្មទាំងនេះ។ ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះ គឺមានជាប់ពាក់ព័ន្ធដល់ថ្នាក់លើទាំងឡាយណាដែលខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះអំពើឧក្រិដ្ឋដែលអ្នកក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្តឬបានបម្រុងនឹងប្រព្រឹត្ត។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការអន្តរតូបនីយកម្មផ្សេងៗទៀត ដូចជា ICTY, ICTR, SCSL និង ICC មានអំណាចផ្ដន្ទាទោសជនទាំងឡាយ ទៅតាមទម្រង់ដូចៗគ្នានឹងការទទួលខុសត្រូវនេះដែរ ដូចជា ការរៀបចំផែនការ[103] ការញុះញង់[104] ការបញ្ជា[105] ការជួយជ្រោមជ្រែង[106] និងការប្រព្រឹត្តិ[107] ព្រមទាំងការ

---

[103] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មាត្រា៧ (១)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា មាត្រា៦ (១)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន Statute, មាត្រា៦ (១)។

[104] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មាត្រា៧ (១)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា មាត្រា៦ (១)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន Statute, មាត្រា៦ (១)។

[105] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មាត្រា៧ (១)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា មាត្រា៦ (១)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន , មាត្រា៦ (១)។ លក្ខន្តិកៈ ទីក្រុងរ៉ូម មាត្រា២៥ (៣ខ)

ខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋនានាក្នុងនាមជាថ្នាក់លើមួយរូប[108]។ ធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវទាំងនេះ និងការដែលអាចយកវាមកអនុវត្តបានចំពោះ ឌុច នៅក្នុងករណីនេះ គឺមានពិភាក្សាដូចខាងក្រោមនេះ។

### ១. បានប្រព្រឹត្ត

*ការប្រព្រឹត្តិដោយផ្ទាល់*

៤១. បើទោះបីជាតាមធម្មតា ឧក្រិដ្ឋមួយគឺច្រើនតែបានប្រព្រឹត្តឡើងដោយមនុស្សតែម្នាក់យ៉ាងណាក្តី ក៏សហចារីជាច្រើនរូបក៏អាចជាប់ពិរុទ្ធពីការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយនោះបានដែរ ប្រសិនបើ "ការប្រព្រឹត្តិរបស់ជនម្នាក់ៗនោះបំពេញគ្រប់ទៅតាមលក្ខខណ្ឌតម្រូវនៃធាតុផ្សំនានា" របស់អំពើឧក្រិដ្ឋមួយឬច្រើនដែលត្រូវបានចោទប្រកាន់នោះ[109]។ អំពើពិរុទ្ធ (*actus reus*) ក្នុងការប្រព្រឹត្តបានកើតឡើង គឺនៅពេលដែលជនជាប់ចោទ "ដោយខ្លួនឯងប្រព្រឹត្តអំពើឧក្រិដ្ឋដែលពាក់ព័ន្ធជាក់ស្តែង ឬបណ្តែតបណ្តោយធ្វើឲ្យមានការខកខានដែលមានពិរុទ្ធនោះ"[110]។ ចំពោះ *ចេតនាឧក្រិដ្ឋ* (*mens rea*) ដែលតម្រូវក្នុងការប្រព្រឹត្តិនោះ គឺជនជាប់ចោទត្រូវមានចេតនាប្រព្រឹត្តបទល្មើសសកម្ម ឬបទល្មើសអកម្ម ឬមាន

---

[106] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មាត្រា៧ (១)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា មាត្រា៦ (១)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន , មាត្រា៦ (១)។ លក្ខន្តិកៈ ទីក្រុងរ៉ូម មាត្រា២៥ (៣គ)

[107] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មាត្រា៧ (១)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា មាត្រា៦ (១)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន , មាត្រា៦ (១)។ លក្ខន្តិកៈ ទីក្រុងរ៉ូម មាត្រា២៥ (៣ក)

[108] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មាត្រា៧ (២)។ លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា មាត្រា៦ (៣)។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន , មាត្រា៦ (៣)។ លក្ខន្តិកៈ ទីក្រុងរ៉ូម មាត្រា២៨ (ខ)

[109] *រដ្ឋអាជ្ញា ទល់នឹង Kajelijeli* សាលក្រម និងការកាត់ទោស អង្គជំនុំជម្រះតុលាការពិសេសសម្រាប់សេរ៉ាលីអូន សំណុំរឿងលេខ. តុលាការពិសេសសម្រាប់សេរ៉ាលីអូន-98-44A-T ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ កថាខ័ណ្ឌ៧៦៤ ("សាល ក្រម *Kajelijeli*") សាលក្រម *Kunarac* កថាខ័ណ្ឌ៣៩០។

[110] សាលក្រម *Kunarac* កថាខ័ណ្ឌ៣៩០ សាលដីកា *Tadic* កថាខ័ណ្ឌ១៨៨។ សាលក្រម *Krstic* កថាខ័ណ្ឌ៦០១។

ចេតនាចង់បណ្តែតបណ្តោយចង់ឱ្យឧក្រិដ្ឋកម្មនោះកើតឡើង[111]។ ឬម្យ៉ាងទៀត ការដឹង ឬការមានអារម្មណ៍ដឹងរបស់ជនជាប់ចោទអំពីភាវនីយភាពសំខាន់ថាបទល្មើសសកម្ម ឬបទល្មើសអកម្ម គឺបណ្តាលមកពីការប្រព្រឹត្តិរបស់ខ្លួននោះ គឺវាជាការគ្រប់គ្រាន់ហើយ [112]។

*តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម*

៤២. ការប្រព្រឹត្តិបទល្មើសអ្វីមួយតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានគេទទួលស្គាល់នៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY, ICTR និង SCSL[113]។ ដោយច្បាប់ អ.វ.ត.ក ត្រូវបានព្រាងឡើងនៅក្រោយពេល បង្កើតលក្ខន្តិកៈនៃតុលាការ ICTY និង ICTR និងមានប្រើភាសាដូចគ្នាស្តីពីទម្រង់នៃការទទួល

[111] សាលក្រម *Limaj* កថាខ័ណ្ឌ៥០៩ សាលក្រម *Simic* កថាខ័ណ្ឌ១៣៧។

[112] សាលក្រម *Kvocka* កថាខ័ណ្ឌ២៥១។

[113] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Milutinovic* និងអ្នកដទៃទៀត សេចក្តីសម្រេចទៅលើញត្តិរបស់ Dragoljub Ojdanic ប្រឆាំងនឹងយុត្តាធិការ é សហកម្មឧក្រិដ្ឋកម្មរួម ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការសាលាឧទ្ធរណ៍ សំណុំរឿងលេខ. IT-99-37-AR72, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ កថាខ័ណ្ឌ២០ (បណ្តឹងឧទ្ធរណ៍ *Milutinovic*") "តុលាការសាលាឧទ្ធរណ៍É ចាត់ទុក សហកម្មឧក្រិដ្ឋកម្មរួម ជាទម្រង់មួយនៃការប្រព្រឹត្ត យោងតាមមាត្រា៧(១) នៃច្បាប់លក្ខន្តិកៈ"។ *រដ្ឋអាជ្ញា ទល់នឹង Gacumbitsi* សាលក្រមតុលាការពិសេសសម្រាប់ សេរ៉ាលីអូន តុលាការសាលាឧទ្ធរណ៍ សំណុំរឿងលេខ តុលាការពិសេសសម្រាប់សេរ៉ាលីអូន-2001-64-A ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០០៦ កថាខ័ណ្ឌ១៥៨។ "តុលាការសាលាឧទ្ធរណ៍ ច្បាប់លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី អ្វីៗធ្លាប់មានពីមុនមកបានបញ្ជាក់ថាជនត្រូវចោទនៅចំពោះមុខសាលាក្តីនេះ អាចនឹងត្រូវបានគេរកឃើញថា ត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ក្នុងអត្ថន័យនៃមាត្រា៦ (១) នៃលក្ខន្តិកៈនេះក្រោមប្រភេទ មួយនៃប្រភេទទាំងបីនៃការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួម"។ *រដ្ឋអាជ្ញា ទល់នឹង Fofana & Kondewa* សាលក្រម ច្បាប់លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់សេរ៉ាលីអូន អង្គជំនុំជម្រះ សំណុំរឿងលេខច្បាប់លក្ខន្តិកៈនៃតុលា ការពិសេសសម្រាប់សេរ៉ាលីអូន -04-14-T ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ កថាខ័ណ្ឌ២០៨ "ការប្រព្រឹត្ត (ដូចដែលបាន ប្រើក្នុងច្បាប់លក្ខន្តិកៈនេះ) គឺអាចប្រែប្រួលរាប់បញ្ចូលទាំងការចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងសហកម្មឧក្រិដ្ឋកម្ម រួម"។

ខុសត្រូវនោះ ដូច្នេះគឺ ភាសាដែលគេប្រើក្នុងមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក គឺគេទំនងជាចង់ដាក់បញ្ចូលនូវសហកម្មឧក្រិដ្ឋកម្មរួមក្នុងនេះផងដែរ[114]។

៤៣. សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវមួយដែលដាក់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ទៅលើបុគ្គលទាំងឡាយ ចំពោះអំពើដែលបានប្រព្រឹត្តឡើងដោយមនុស្សមួយក្រុមជាសមូហភាព ដើម្បីជួយជំរុញធ្វើឱ្យបានសម្រេចនូវគំរោងការណ៍ឧក្រិដ្ឋកម្មរួមមួយ[115]។ បើទោះបីជាពាក្យបច្ចេកទេសនៃ"សហកម្មឧក្រិដ្ឋកម្មរួម" វាថ្មីបន្តិចក៏ដោយ ក៏ទស្សនៈទានផ្នែកច្បាប់ជាមូលដ្ឋានរបស់វា គឺមានស្រាប់រួចមកហើយ ទាំងនៅក្នុងច្បាប់ជាតិ និងទាំងក្នុងច្បាប់អន្តរជាតិ យ៉ាងហោចណាស់ចាប់តាំងពីសង្គ្រាមលោកលើកទី២មកម្ល៉េះ។ មានការជំនុំជម្រះក្តីព្រហ្មទណ្ឌរាប់ពាន់ករណីលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តកាលពីក្នុងអំឡុងសង្គ្រាមលោកលើកទី២ ដែលមានទាំងលក្ខណៈជាតិផង និងអន្តរជាតិផង។ ការជំនុំជម្រះក្តីទាំងនេះបានរកឃើញថា បុគ្គលទាំងឡាយអាចត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌក្នុងនាមជា សហចារីចំពោះការចូលរួមរបស់ខ្លួននៅក្នុងផែនការ ឬគំរោងការណ៍ឧក្រិដ្ឋកម្មរួម ដែលបើទោះបីជាទម្រង់នៃការទទួលខុសត្រូវនោះ គេមិនបានហៅថា ជាសហកម្មឧក្រិដ្ឋកម្មរួមក៏ដោយ។

---

114 ការបកស្រាយនេះនឹងមានភាពរលូនជាមួយនឹងគោលបំណងនៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ គោលបំណងសំខាន់នៃអ.វ.ត.ក គឺដើម្បីកាត់ទោសពួកមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជា ប្រជាធិបតេយ្យ ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា មាត្រា១។ ក្នុងការកាត់ទោសអ្នកទាំងនោះ វាមានការចាំបាច់ដែលអ.វ.ត.ក ត្រូវមានយុត្តាធិការ ទៅលើ អ្នកដែលបានបង្កើត និងរៀបចំគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនិស្តកម្ពុជា មិនមែនជាជនដៃដល់នោះ ទេ។ ហេតុដូច្នេះ ការបកស្រាយមាត្រា២៩ ដើម្បីរាប់បញ្ចូលសហកម្មឧក្រិដ្ឋកម្មរួម គឺនឹងមានភាពរលូននឹងគោល បំណងរបស់ច្បាប់ អ.វ.ត.ក។ *សូមមើល* សាលដីកា *Tadic* កថាខ័ណ្ឌ១៨៩-១៩០។

115 សាលដីកា *Tadic* កថាខ័ណ្ឌ១៩៣ ១៨៧-២២៦។ *សូមមើលផងដែរ* សាលដីកា *Vasiljevic* កថាខ័ណ្ឌ៩៥ ៩៦។

៤៤. នៅឆ្នាំ១៩៤៥ មាត្រា៦ នៃធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ(IMT)[116] បានចែងថា បុគ្គលទាំងឡាយដែល "ចូលរួមក្នុងការបង្កើត ឬការអនុវត្តផែនការរួម ឬការរួមគំនិត" ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព គឺត្រូវតែ "ទទួលខុសត្រូវចំពោះគ្រប់អំពើទាំងអស់ ដែលប្រព្រឹត្តឡើងដោយជនណាម្នាក់ក្នុងការអនុវត្តផែនការរួមនោះ"។ ឃើញមានបទបញ្ញត្តិដូចគ្នានេះដែរ ដែលចែងនៅក្នុងមាត្រា៥ នៃតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ាឆ្នាំ១៩៤៦[117]។ នៅក្នុងមាត្រា II នៃច្បាប់គ្រប់គ្រងក្រុមប្រឹក្សា (Control Council Law) លេខ១០ (១៩៤៥) ក៏បានពង្រីកបន្ថែមការទទួលខុសត្រូវនេះរហូតទៅដល់បុគ្គលទាំងឡាយណាដែលមានការ "ជាប់ទាក់ទងគ្នាជាមួយនឹងផែនការផ្សេងៗឬសហកម្មរួមនេះ" ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[118]។ ដូចដែលអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY បានបង្ហាញក្នុងករណីរឿងក្តីរបស់ *Tadic* គឺមានការជំនុំជម្រះក្តី សង្គ្រាមលោកលើកទី២ ជាច្រើន ដែលក្នុងនោះមានមនុស្សដែលត្រូវបានរកឃើញថាបានទទួលខុសត្រូវចំពោះការចូលរួមរបស់ខ្លួន នៅក្នុងផែនការឧក្រិដ្ឋកម្មរួម ឬក្នុងបំណងឧក្រិដ្ឋកម្មរួម[119]។

៤៥. ទោះបីទស្សនទាននៃសហកម្មឧក្រិដ្ឋរួមទើបតែលេចចេញជាលើកដំបូងនៅក្នុងច្បាប់អន្តរជាតិ បន្ទិចក្រោយពីសង្គ្រាមលោកលើកទី២យ៉ាងណាក្តី ក៏វាមិនមែនជាគោលគំនិតថ្មីដែរនៅពេលនោះ។ ផ្ទុយទៅ

---

[116] *សូមមើល* ធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ *ជាឧបសម្ព័ន្ធនឹង* កិច្ចព្រមព្រៀង ដើម្បីការកាត់ទោស និងការដាក់ ទោសឧក្រិដ្ឋជនសង្គ្រាមធំៗ នៃសម្ពន្ធមិត្តអឺរ៉ុប មាត្រា៦ ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៤៥ បោះពុម្ពឡើងវិញនៅ ក្នុង *ការកាត់ទោសមេឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗក្នុងតុលាការយោធាអន្តរជាតិ ១០-១១ ឆ្នាំ១៩៤៧ (TRIAL OF THE MAJOR WAR CRIMINALS BEFORE THE INTERNATIONAL MILITARY TRIBUNAL 10-11 (1947)*។

[117] *សូមមើល* ធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិសំរាប់ចុងបូព៌ា ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ ដែលអាចរកបានក្នុង Gabrielle Kirk McDonald & Olivia Swaak-Goldman eds., Substantive and Procedural Aspects of International Criminal Law, Volume II: Documents and Cases (2000) ទំព័រ៧៣-៧៧។

[118] ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ ស្តីពី ការដាក់ទណ្ឌកម្មលើជនដែលមានពិរុទ្ធពីឧក្រិដ្ឋជនសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥ (Control Council Law No. 10, Punishment of Persons Guilty of War Crimes, Crimes Against Peace and Against Humanity,) រាជកិច្ចទាំង៣ នៃក្រុមប្រឹក្សាត្រួតពិនិត្យប្រទេសអាល្លឺម៉ង់ ទំព័រ៥០-៥៥ (1946)។

[119] សាលដីកា *Tadic* កថាខ័ណ្ឌ ១៩៥-២២០។

វិញ ទស្សនទានដែលថា បុគ្គលច្រើនរូបអាចត្រូវទទួលខុសត្រូវស្មើៗគ្នាចំពោះអំពើឧក្រិដ្ឋ ដែលបណ្តាលមកពីការចូលរួមក្នុងផែនការឧក្រិដ្ឋកម្ម និងគំរោងការណ៍រួមនេះ គឺមានដើមកំណើតតាំងពីយូរណាស់មកហើយនៅក្នុងច្បាប់ជាតិរបស់ប្រទេសផ្សេងៗ និងមានទាំងនៅក្នុងយុត្តាធិការនៃប្រព័ន្ធច្បាប់ common law និង civil law ទៀតផង[120]។ គោលគំនិតនេះក៏ធ្លាប់ឃើញមាននៅក្នុងច្បាប់របស់កម្ពុជាតាំងពីមុនពេលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មផ្សេងៗ ដូចដែលបានពិពណ៌នានៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះផងដែរ។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា ជនណាដែលចូលរួមដោយស្ម័គ្រចិត្តក្នុងបទឧក្រិដ្ឋណាមួយ ទោះបីជាចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្តី គឺត្រូវទទួលខុសត្រូវស្មើគ្នានឹងមេគំនិតនៃបទឧក្រិដ្ឋនោះដែរ[121]។ ហេតុដូច្នេះហើយ **ឌុច** អាចនឹងត្រូវគេរំពឹងទុកដោយសមហេតុ សមផលថា គាត់មុខជាត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះអំពើទាំងឡាយដែលបុគ្គលិកនៃមន្ទីរ ស-២១ ដទៃៗទៀតបានអនុវត្ត ប្រសិនជាពួកបុគ្គលិកទាំងនេះបានអនុវត្តស្របទៅតាមផែនការឧក្រិដ្ឋកម្ម ឬគំរោងការណ៍រួម[122]។

---

[120] សាលដីកា *Tadic* កថាខ័ណ្ឌ២២៤ ពិភាក្សាអំពីដើមហេតុនៃទស្សនៈទាន ស្រដៀងទៅនឹងសហកម្មឧក្រិដ្ឋកម្មរួមក្នុងយុត្តិសាស្ត្រនៃរដ្ឋផ្សេងៗ។

[121] ក្រមព្រហ្មទណ្ឌ និងច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មាត្រា៨២ "បុគ្គលណាដែលចូលរួម "Toute personne participant volontairement, soit directement, soit indirectement, » la perp"tration d"un crime or d"un d"lit, est passible des peines applicables » l"auteur principal."

[122] **ឌុច** អាចដាក់ឲ្យទទួលខុសត្រូវចំពោះការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម ប្រសិនបើការទទួលខុសត្រូវនោះអាចត្រូវបានគេប្រមើលឃើញ និងប្រសិនបើច្បាប់ស្តីពីសហកម្មឧក្រិដ្ឋកម្មរួមមាននៅក្នុងពេលមានការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មនោះ បណ្តឹងឧទ្ធរណ៍សហកម្មឧក្រិដ្ឋកម្មរួម *Milutinovic* កថាខ័ណ្ឌ៣៧ ច្បាប់លក្ខន្តិកៈ នៃ IMT និង IMTFE Control Council Law no. 10 ព្រមទាំងការជម្រះក្តីសង្គ្រាមលោកលើកទី២ មួយចំនួនធំទាក់ទិននឹងគោលបំណងឧក្រិដ្ឋរួម ឬការរៀបចំដែលបានពិភាក្សាមកខាងលើបង្ហាញថាការទទួលខុសត្រូវគឺបានត្រូវគេសម្លឹងឃើញ ហើយមូលដ្ឋាននៃការទទួលខុសត្រូវនោះគឺអាចវាយតម្លៃបាន។ នៅក្នុងបណ្តឹងឧទ្ធរណ៍សហកម្មឧក្រិដ្ឋកម្មរួម *Milutinovic* កថា ខ័ណ្ឌ៤១ ការធ្វើ សេចក្តីសន្និដ្ឋានបានត្រូវពង្រឹងដោយការពិតដែលថាទង្វើដែលបានចោទប្រកាន់ គឺជាទង្វើឧក្រិដ្ឋស្ថិតនៅក្រោមក្រមព្រហ្ម ទណ្ឌឆ្នាំ១៩៥៦។ សហកម្មឧក្រិដ្ឋកម្មរួម *Milutinovic* កថាខ័ណ្ឌ៤០ ជាចុងក្រោយសារជាតិ និងវិសាលភាពនៃឧក្រិដ្ឋ កម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរស២១ កាត់បន្ថយនូវការលើកឡើងនូវទឡ្ហីករណ៍ថាអ្នកចូលរួម មិនបានដឹងថាទង្វើរបស់ ពួកគេនោះ ជាអំពើឧក្រិដ្ឋកម្មបណ្តឹងឧទ្ធរណ៍ សហកម្មឧក្រិដ្ឋកម្មរួម *Milutinovic* កថាខ័ណ្ឌ៤២។

៤៦. ទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមមានបីខុសៗគ្នា ប៉ុន្តែពាក់ព័ន្ធគ្នាទៅវិញទៅមក ជាមូលដ្ឋាន (Basic): ជនជាប់ចោទដែលជាអ្នកចូលរួមទាំងអស់ ប្រព្រឹត្តទៅតាមគំរោងការណ៍ឧក្រិដ្ឋកម្មរួម ហើយអ្នកទាំងអស់នោះសុទ្ធតែមានចេតនាឧក្រិដ្ឋដូចៗគ្នា នៅពេលដែលខ្លួនកំពុងបំពេញនូវគំរោងការណ៍ឧក្រិដ្ឋរួមនោះ[123]។ ជាលក្ខណៈប្រព័ន្ធ (Systematic): ជនជាប់ចោទដែលបានចូលរួមទាំងអស់គ្នា ប្រព្រឹត្តទៅតាមការរៀបចំផែនការឧក្រិដ្ឋកម្មរួម ហើយអ្នកទាំងអស់នោះសុទ្ធតែមានចេតនាឧក្រិដ្ឋ ដូចៗគ្នា នៅក្នុងពេលដែលខ្លួនកំពុងបំពេញនូវគំរោងការណ៍ឧក្រិដ្ឋកម្មរួមនោះ ហើយបទឧក្រិដ្ឋដែលបានចោទប្រកាន់ទាំងនោះបានកើតមានឡើងក្នុងបរិបទនៃគំរោងការណ៍ឧក្រិដ្ឋកម្មរួមដែល *តាមធម្មតា* គឺធ្វើ ឡើងដោយសមាជិកនៃអង្គភាព យោធា ឬរដ្ឋបាលមួយ[124]។ ជាឧទាហរណ៍ ទម្រង់នៃសហកម្មឧក្រិដ្ឋកម្មរួមនេះមានការជាប់ទាក់ទងគ្នាទៅនឹងជំរុំប្រមូលផ្តុំ ឬជំរុំសម្រាប់សម្លាប់បំផុតពូជ ឬ "ប្រព័ន្ធចាត់តាំងដើម្បីធ្វើបាប" ណាមួយ[125]។ អត្ថិភាព និង/ឬសមាជិកភាពនៅក្នុងអង្គភាពយោធា ឬរដ្ឋបាលគឺមិនមែនជាតម្រូវការឲ្យមានជាផ្លូវការនោះទេ ក៏ប៉ុន្តែវាគ្រាន់តែការចង្អុលបង្ហាញអំពីប្រព័ន្ធចាត់តាំងដើម្បីធ្វើបាបមួយតែប៉ុណ្ណោះ[126]។ ត្រូវបានពង្រីកបន្ថែម (Extended): ជនជាប់ចោទដែលជាអ្នកចូលរួមទាំងអស់ ប្រព្រឹត្តទៅតាមគំរោងការណ៍ឧក្រិដ្ឋកម្មរួម ហើយអ្នកទាំងអស់នោះសុទ្ធតែមានចេតនាឧក្រិដ្ឋដូចៗគ្នា នៅពេលខ្លួនកំពុងបំពេញនូវគំរោងការណ៍ឧក្រិដ្ឋកម្មរួមនោះ ហើយដែលមានអ្នកចូលរួមម្នាក់ប្រព្រឹត្តអំពើមួយ ដែលទោះបីជាស្ថិតនៅក្រៅពីរង្វង់នៃគោលបំណងឧក្រិដ្ឋកម្មដើមក៏ដោយ ក៏ត្រូវតែកំណត់ថាសមាជិកដទៃទៀតក៏ជាប់ពាក់ព័ន្ធដូចគ្នាដែរ ដោយសារតែអំពើ នោះមាន "ព្យសនកម្មបែបធម្មជាតិ និងដែលអាចឲ្យគេរំពឹងទុកជាមុនបាន" អំពីគំរោងការណ៍ឧក្រិដ្ឋកម្មនោះ[127]។

---

[123] សាលដីកា *Tadic* កថាខ័ណ្ឌ១៩៦ សាលដីកា *Vasiljevic*, កថាខ័ណ្ឌ៩៧។ *សូមមើលផងដែរ* សាលដីកា *Krnojelac* កថាខ័ណ្ឌ ៨៣-៨៤ ពិភាក្សាអន្តរកម្មរវាងទម្រង់មូលដ្ឋាននៃសហកម្មឧក្រិដ្ឋកម្មរួម និងទំរង់នៃសហកម្មឧក្រិដ្ឋកម្ម រួមដែលបានត្រូវពង្រីក។

[124] សាលដីកា *Tadic* កថាខ័ណ្ឌ២០២។

[125] សាលដីកា *Vasiljevic* កថាខ័ណ្ឌ៩៨។

[126] សាលដីកា *Krnojelac* កថាខ័ណ្ឌ៨៩។ សាលដីកា *Kvocka* កថាខ័ណ្ឌ១៨២។

[127] សាលដីកា *Tadic* កថាខ័ណ្ឌ២០៤។ ឧទាហរណ៍មួយនៃករណីនេះ គឺបំណងឧក្រិដ្ឋរួមដើម្បីបោសសម្អាតជាតិពន្ធ នៅក្នុងតំបន់ណាមួយដោយចុងកាណុង ប៉ុន្តែជាមួយនឹងចេតនាឧក្រិដ្ឋរួមដើម្បីគ្រាន់តែនឹងនិរទេសមនុស្សដែលគេមិនត្រូវការចេញពីតំបន់នោះប៉ុណ្ណោះ។ ក្នុងអំឡុងប្រតិបត្តិការនោះ មានមនុស្សបានត្រូវគេបាញ់ប្រហារ និងសម្លាប់។ ខណៈពេល ដែលបំណងឧក្រិដ្ឋរួម អាចជា

៤៧. អំពើពិរុទ្ធ(*actus reus*) នៃសហកម្មឧក្រិដ្ឋកម្មរួមគ្រប់ប្រភេទទាំងអស់មានធាតុផ្សំចំនួនបី។ <u>ទី១</u> ចាំបាច់ត្រូវតែមាន "ពហុភាពនៃមនុស្ស"[128]។ ក្រុមមនុស្សនេះមិនចាំបាច់តម្រូវឱ្យមានការរៀបចំជារចនាសម្ព័ន្ធផ្លូវការឬមិនផ្លូវការទេ ដូចជា អង្គការយោធា នយោបាយ ឬរដ្ឋបាល[129] ។ <u>ទី២</u> គំរោងការណ៍ឬគោលបំណងឧក្រិដ្ឋកម្មរួម គឺមិនចាំបាច់តម្រូវឱ្យជាប់ពាក់ព័ន្ធគ្នាទៅនឹងសកម្មភាពឧក្រិដ្ឋកម្មដែលហាមឃាត់ដោយលក្ខន្តិកៈរបស់តុលាការដែលមានយុត្តាធិការលើជនជាប់ចោទនោះទេ[130]។ ផែនការ ឬគំរោងការណ៍ ឬគោលបំណងឧក្រិដ្ឋកម្មរួម គឺមិនចាំបាច់ត្រូវតែរៀបចំឡើងឬបង្កើតឡើងតាំងពីមុនមកនោះទេ[131]។ ចារីនៃបទឧក្រិដ្ឋ និងជនជាប់ចោទ មិនចាំបាច់តម្រូវឱ្យដឹងជាក់លាក់ ឬមានការព្រមព្រៀងគ្នាទៅវិញទៅមកក្នុងចំណោមពួកគេអំពីការប្រព្រឹត្តិអំពើឧក្រិដ្ឋទាំងនោះទេ[132]។ លើសពីនេះទៅទៀត ផែនការឧក្រិដ្ឋកម្ម ឬគោលបំណងរួមនេះអាចរកឃើញបានដោយមិនចាំបាច់មានការព្រាងទុកជាមុនទេ និងអាចធ្វើការសន្និដ្ឋានបានដោយទាញចេញមកពីអង្គហេតុទាំងនោះ[133]។ <u>ទី៣</u> ជនជាប់ចោទត្រូវតែបានចូលរួមក្នុងតួនាទីអ្វីមួយក្នុងគំរោងការណ៍ឧក្រិដ្ឋកម្មរួមនោះ[134]។ ការចូលរួមរបស់ជនជាប់ចោទមិនតម្រូវឱ្យមានជាចាំបាច់នោះទេ[135] ប៉ុន្តែត្រូវតែសំខាន់ដើម្បីអនុវត្តនូវ

---

ការបោសសម្អាតជាតិពន្ធនៅក្នុងតំបន់នោះ តែមិនមែនជាការប្រព្រឹត្តអំពើមនុស្សឃាតនោះ វាជាហេតុបច្ច័យមួយដែលយើងអាចព្យាករណ៍ និងប៉ាន់ស្មានបានថា មនុស្សនឹងអាចត្រូវគេសម្លាប់ ប្រសិនបើជនដែលដល់ក្នុង យុទ្ធនាការបោសសម្អាតជាតិពន្ធនោះមានអាវុធជាប់ខ្លួន។ សាលដីកា *Vasiljevic* កថាខ័ណ្ឌ៩៩។

[128] សាលដីកា *Vasiljevic* កថាខ័ណ្ឌ១០០។ *សូមមើល* សាលដីកា *រដ្ឋអាជ្ញា ទល់នឹង Stakic* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សំណុំរឿងលេខ. IT-97-24-A ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខ័ណ្ឌ៦៤ ("សាលដីកា *Stakic*")។

[129] សាលដីកា *Krnojelac* កថាខ័ណ្ឌ៣១។ សាលដីកា *Vasiljevic* កថាខ័ណ្ឌ១០០។

[130] សាលដីកា *Tadic* កថាខ័ណ្ឌ២២៧។ សាលដីកា *Vasiljevic* កថាខ័ណ្ឌ១០០។

[131] សាលដីកា *Tadic* កថាខ័ណ្ឌ២២៧។ សាលដីកា *Stakic* កថាខ័ណ្ឌ៦៤។

[132] សាលដីកា *Tadic* កថាខ័ណ្ឌ២២៧។ សាលដីកា *Vasiljevic* កថាខ័ណ្ឌ១០០។ សាលដីកា *រដ្ឋអាជ្ញា ទល់នឹង Brdanin* តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-99-36-A ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខ័ណ្ឌ ៤១៨ ("សាលដីកា *Brdanin*")។

[133] សាលដីកា *Tadic* កថាខ័ណ្ឌ ២២៧។ សាលដីកា *Krnojelac* កថាខ័ណ្ឌ៣១។

[134] សាលដីកា *Tadic* កថាខ័ណ្ឌ ២២៧។ សាលដីកា *Stakic* កថាខ័ណ្ឌ៦៤។ សាលដីកា *Brdanin* កថាខ័ណ្ឌ៤១៨។

[135] សាលដីកា *Kvocka* កថាខ័ណ្ឌ៩៨។

ផែនការរួម[136] ។ វត្តមានរបស់ជនជាប់ចោទនៅក្នុងពេលប្រព្រឹត្តអំពើឧក្រិដ្ឋ គឺមិនចាំបាច់តម្រូវឲ្យមានទេ[137]។

៤៨. ទោះបីជាទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួមនេះមានធាតុផ្សំនៃ*អំពើពិរុទ្ធ* (*actus reus*) ដូចៗគ្នានោះ ក៏ធាតុផ្សំនៃសហកម្មឧក្រិដ្ឋកម្មរួមទាំងនោះមិនមាន*ចេតនាឧក្រិដ្ឋ* (*mens rea*) រួមតែមួយដូចគ្នានោះដែរ។ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ជាមូលដ្ឋាន (basic) គឺតម្រូវឲ្យជនជាប់ចោទមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋមួយឬច្រើនដូចដែលបានចោទប្រកាន់ ហើយអ្នកចូលរួមទាំងអស់នៅក្នុងគំរោងការ ឧក្រិដ្ឋកម្មរួមនោះត្រូវមានចេតនារួមតែមួយដូចគ្នា[138]។ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ជាលក្ខណៈប្រព័ន្ធ (systematic) គឺទាមទារតម្រូវឲ្យអ្នកចូលរួមមានកម្រិតចេតនាឧក្រិដ្ឋស្រដៀងគ្នានេះដែរៈ ជនជាប់ចោទត្រូវតែបានដឹងដោយខ្លួនឯងផ្ទាល់អំពីប្រព័ន្ធសម្រាប់ការធ្វើបាប និងមានចេតនាចង់ជួយជំរុញធ្វើឲ្យប្រព័ន្ធបែបហ្នឹងរីកចម្រើនតទៅមុខទៀត[139]។ សមាជិកទាំងឡាយនៃសហកម្មឧក្រិដ្ឋកម្មរួមអាចត្រូវទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តជាក់ស្តែងដោយអ្នកមកពីក្រៅរង្វង់នៃ សហកម្មឧក្រិដ្ឋកម្មរួមនេះ ប្រសិនបើបទឧក្រិដ្ឋទាំងនេះបង្កើតបានជាផ្នែកមួយនៃគោលបំណងឧក្រិដ្ឋកម្មរួម និងដោយមានសមាជិកណាម្នាក់នៃសហកម្មឧក្រិដ្ឋកម្មរួមនេះ ប្រើប្រាស់ភាគីពីខាងក្រៅ ម្នាក់ឬច្រើននាក់ធ្វើជាឧបករណ៍ដើម្បីអនុវត្តនូវគោលបំណងឧក្រិដ្ឋកម្មរួមនេះ[140]។

---

[136] សាលដីកា *Brdjanin* កថាខ័ណ្ឌ៤៣០។

[137] សាលដីកា *Krnojelac* កថាខ័ណ្ឌ៨១។

[138] សាលដីកា *Tadic* កថាខ័ណ្ឌ២២០ ២២៨។

[139] សាលដីកា *Krnojelac* កថាខ័ណ្ឌ ៣២។ សាលដីកា *Vasiljevic* កថាខ័ណ្ឌ ១០១ ១០៥។

[140] សាលដីកា *Brdjanin* កថាខ័ណ្ឌ៤១០ ៤១៣ ៤១៨ ៤៣០ "ពេលសមាជិកម្នាក់នៃក្រុមសហកម្មឧក្រិដ្ឋកម្មរួម(JCE) ប្រើប្រាស់មនុស្សណាម្នាក់ដែលស្ថិតនៅខាងក្រៅសហកម្មឧក្រិដ្ឋកម្មរួម ដើម្បីអនុវត្តអំពើពិរុទ្ធនៃឧក្រិដ្ឋកម្មមួយ ដោយបុគ្គលនោះ (មនុស្សខាងក្រៅ) ដឹងឮអំពីអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួម ឧទាហរណ៍ដូចជាគោលបំណងរួមជាដើម ក៏អាចជាកត្តាមួយដែលអាចយកមកធ្វើការពិចារណា ពេលកំណត់ថាតើបទឧក្រិដ្ឋនោះបង្កើតបានជាផ្នែកមួយនៃគោលបំណងឧក្រិដ្ឋរួមដែរឬទេ"។ សាលក្រម *Mrksic* កថាខ័ណ្ឌ ៥៤៧ (កំណត់សម្គាល់ពន្យល់ បានបន្ថែម)។

៤៩. ចំពោះទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ដែលត្រូវបានពង្រីកបន្ថែម (extended JCE) វិញ គឺតម្រូវចាំបាច់ឱ្យជនជាប់ចោទត្រូវមានចេតនាចូលរួម និងបានជួយរួមចំណែកនៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួមនោះ។ ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងឡាយដែលមិនមែនជាផ្នែកមួយនៃគោលបំណងឧក្រិដ្ឋកម្មរួម ប៉ុន្តែវាជាផលវិបាកធម្មជាតិ និងដែលអាចរំពឹងទុកជាមុនបាននៃគោលបំណងឧក្រិដ្ឋកម្មរួមនោះ គឺតម្រូវឱ្យមានធាតុផ្សំបន្ថែមចំនួនពីរទៀត។ គឺជនជាប់ចោទត្រូវតែដឹងថា ឧក្រិដ្ឋកម្មទាំងនេះអាចនឹងត្រូវប្រព្រឹត្តឡើងដោយសមាជិកណាម្នាក់នៃក្រុមនោះ ហើយត្រូវមានចេតនា ចង់ប្រថុយចំពោះហានិភ័យនោះដោយការចូលរួម ឬបន្តចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះ[141]។ ប្រសិនបើមានចារីណាម្នាក់ពីខាងក្រៅប្រព្រឹត្តបទឧក្រិដ្ឋ ហួសពីវិសាលភាពនៃសហកម្មឧក្រិដ្ឋកម្មរួមគឺជនជាប់ចោទនោះត្រូវទទួលខុសត្រូវនៅក្រោមទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ដែលត្រូវបានពង្រីកបន្ថែមនេះ បើសិនជា:

(ក) ជនជាប់ចោទបានចូលរួមក្នុងគំរោងការណ៍ឧក្រិដ្ឋកម្មរួមដោយមានចេតនា ដូចដែលលក្ខខណ្ឌតម្រូវឱ្យមាន។

(ខ) ការប្រព្រឹត្តិឧក្រិដ្ឋកម្មនេះ ដែលប្រព្រឹត្តឡើងដោយចារីពីខាងក្រៅគឺមានផលវិបាកជាធម្មជាតិ និង អាចរំពឹងទុកជាមុនបានអំពីគោលបំណងសហកម្មឧក្រិដ្ឋកម្មរួមនោះ។ និង

(គ) ទោះបីជាជនជាប់ចោទមានចេតនាចង់ប្រថុយចំពោះហានិភ័យនេះដូចនេះក្តី ក៏នៅតែសម្រេចចិត្តចូលរួមក្នុងគោលបំណងសហកម្មឧក្រិដ្ឋកម្មរួមនោះទៀត[142]។

៥០. យុត្តិសាស្ត្រដែលទាក់ទងយ៉ាងជាក់លាក់ទៅនឹងមណ្ឌលឃុំឃាំងនានា បានរកឃើញថា ឧក្រិដ្ឋកម្មនានានៅទីនោះ គឺអ្នកជាប់ឃុំឃាំងត្រូវបានគេដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ឱ្យស្ថិតនៅក្នុងសភាពដ៏អមនុស្សធម៌ ដែលទទួលរងនូវការវាយដំ ការធ្វើទារុណកម្ម និងការកំទេចចោល ដែលឧក្រិដ្ឋកម្មទាំងនេះ បង្ហាញឱ្យឃើញថាសហកម្មឧក្រិដ្ឋកម្មរួមបានកើតឡើង[143]។ ដូចគ្នានេះដែរ មេបញ្ជាការ ឬមេបញ្ជាការរងទាំងឡាយក៏ត្រូវបានគេរកឃើញថា គឺជាសហចារីនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម

---

[141] សាលដីកា *Kvocka* កថាខណ្ឌ៨៣។ សាលដីកា *Tadic* កថាខណ្ឌ២២៨។ សាលក្រម *Mrksic* កថាខណ្ឌ៥៤៦។

[142] សាលដីកា *Brdjanin* កថាខណ្ឌ៤១១ ៤៣១។

[143] សាលក្រម *Kvocka* កថាខណ្ឌ៣២០។ សាលដីកា *Krnojelac* កថាខណ្ឌ១១០-១១១។

នៅតាមមណ្ឌលឃុំឃាំងទាំងនេះដែរ។ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី កត្តាផ្សេងៗដែលចង្អុលបង្ហាញឱ្យឃើញថាមានសហកម្មឧក្រិដ្ឋកម្មរួមបែបដូចនេះ ត្រូវបានគេកត់សំគាល់ដូចខាងក្រោមនេះ:

(ក) ការពិតអំពីឆ្មាំយាមបានទៅស្នើសុំការណែនាំពីមេបញ្ជាការ ហើយមេបញ្ជាការបានឱ្យបញ្ជាទៅ ហើយឆ្មាំយាមទាំងនោះក៏បានអនុវត្តបញ្ជានោះ[144] ។

(ខ) ការចូលរួមចំណែកជាសារវន្តនៃវត្តមានរបស់មេបញ្ជាការ នៅក្នុងដំណាក់កាលដំបូងនៃអត្ថិភាពនៃមណ្ឌលឃុំឃាំង ការចូលរួមរបស់គាត់នៅក្នុងការរៀបចំបង្កើតមណ្ឌលនេះ និងបទពិសោធន៍របស់គាត់ក្នុងនាមជាមន្ត្រីនគរបាលមួយរូប[145] និង

(គ) តួនាទីជាគន្លឹះរបស់មេបញ្ជាការ គឺនៅក្នុងដំណើរការប្រចាំថ្ងៃ និងការថែរក្សាមណ្ឌលឃុំឃាំងដែលសុទ្ធតែជាការរួមចំណែកនៅក្នុងការអនុវត្តនូវឧក្រិដ្ឋកម្មដែលរើសអើងទាំងនេះ[146]។

## ២. បានបញ្ជា

៥១. អំពើនៃការបញ្ជាបានកើតឡើងនៅពេលដែល "ជនណាម្នាក់ក្នុងមុខតំណែងដែលមានអំណាច ហើយប្រើប្រាស់មុខតំណែងនោះ ដើម្បីបញ្ចុះបញ្ចូលជនណាម្នាក់ទៀតឱ្យប្រព្រឹត្តអំពើឧក្រិដ្ឋណាមួយ"[147]។ បញ្ជាជាក់ស្តែងនោះមិនចាំបាច់តម្រូវថាជាបញ្ជាមិនស្របច្បាប់ ឬក៏មិនចាំបាច់ថា បញ្ជានោះត្រូវតែធ្វើឡើងដោយផ្ទាល់ ឬដោយបុគ្គលជាប់ចោទខ្លួនឯងផ្ទាល់ទៅដល់សហចារីនោះទេ[148]។ ការចេញ

[144] សាលក្រម *Kvocka* កថាខ័ណ្ឌ៣៩៦។

[145] សាលក្រម *Kvocka* កថាខ័ណ្ឌ៣៩៨-៣៩៩។

[146] សាលក្រម *Kvocka* កថាខ័ណ្ឌ៤០៦-៤០៧។

[147] សាលក្រម *Krstic* កថាខ័ណ្ឌ៦០១។ សាលក្រម Akayesu កថាខ័ណ្ឌ៤៨៣។ សាលក្រម *Bagilishema* កថាខ័ណ្ឌ៣១ *សូមមើលផងដែរ* ច្បាប់អ.វ.ត.ក មាត្រា២៩ លក្ខន្តិកៈ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី មាត្រា ៧(១) លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា មាត្រា៦ (១) លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ សេរ៉ាលីអូន មាត្រា៦ (១) ។

[148] សាលក្រម *Blaskic* កថាខ័ណ្ឌ២៨១-២៨២។

បញ្ជាណាមួយឡើងវិញ ដោយដាក់ចេញនូវបញ្ជាដែលខុសច្បាប់បន្តទៅតាមខ្សែរយៈនៃការបញ្ជាចុះទៅឱ្យថ្នាក់ក្រោម គឺបង្កើតទៅជាការទទួលខុសត្រូវខាងព្រហ្មទណ្ឌប្រហាក់ប្រហែលគ្នា[149]។ ជនជាប់ចោទត្រូវតែមានអំណាចក្នុងការចេញបញ្ជា ដើម្បីឱ្យកើតបានជាការទទួលខុសត្រូវ ប៉ុន្តែយុត្តិសាស្ត្រមិនទាន់ចែងឱ្យបានច្បាស់លាស់នៅឡើយអំពីថា តើទំនាក់ទំនងជាផ្លូវការរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់ គឺជាលក្ខខណ្ឌដែលចាំបាច់តម្រូវឱ្យមានដែរឬទេ?[150]។ បញ្ជា អាចជាបញ្ជាដោយផ្ទាល់ ឬដោយប្រយោល ហើយត្រូវតែបង្ហាញភស្តុតាងទៅតាមកាលៈទេសៈនីមួយៗ[151]។ ចំពោះចេតនាវិញ គឺតម្រូវឱ្យជនជាប់ចោទត្រូវតែមានចេតនាដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលឱ្យមានការប្រព្រឹត្តិនូវអំពើឧក្រិដ្ឋជាមូលដ្ឋានទាំងនោះ[152]។ ជនជាប់ចោទត្រូវតែបានដឹងថា ការអនុវត្តតាមបញ្ជានោះមុខជានឹងធ្វើឱ្យមានភវនីយភាពដែលមានសារៈសំខាន់ថា ការប្រព្រឹត្តិអំពើឧក្រិដ្ឋណាមួយប្រាកដជានឹងកើតឡើងជាពុំខាន[153]។

៥២. យុត្តិសាស្ត្រដែលទាក់ទងយ៉ាងជាក់លាក់ទៅនឹងមណ្ឌលឃុំឃាំងនានា បានរកឃើញថា មេបញ្ជាការមណ្ឌលឃុំឃាំងទាំងឡាយអាចត្រូវចាប់បង្ខំឱ្យទទួលខុសត្រូវចំពោះការដែលបានចេញបញ្ជាឱ្យធ្វើបាបជនជាប់ឃុំឃាំងនៅក្នុងពេលសួរចម្លើយ[154] ក៏ដូចជាចំពោះការបញ្ជាឱ្យប្រព្រឹត្តអំពើហិង្សាធ្ងន់ធ្ងរចំពោះជនជាប់ឃុំឃាំង ដែលជារឿយៗពួកគេតែងតែទទួលរងនូវការវាយដំ បន្ទាប់ពីប្រធានមណ្ឌលឃុំឃាំង ដែលពីដំបូងបាននាំឆ្មាំពន្ធនាគារជាច្រើនដែលបានវាយដំអ្នកជាប់ឃុំឃាំងឱ្យមកកាន់បន្ទប់ឃុំឃាំងរបស់ជនជាប់ឃុំឃាំងទាំងនោះ[155]។ មានប្រធានមណ្ឌលឃុំឃាំងមួយរូបត្រូវបានគេផ្តន្ទាទោស

---

[149] សាលក្រម *Kupreskic* កថាខ័ណ្ឌ៨២៧ ៦១៣។

[150] សាលក្រម *Akayesu* កថាខ័ណ្ឌ៤៨៣។ សាលក្រម *Blaskic* កថាខ័ណ្ឌ២៨០-២៨១។ សាលក្រម *Kajelijeli* កថាខ័ណ្ឌ៧៦៣។ សាលក្រម *Stakic* កថាខ័ណ្ឌ៤៤៥។

[151] សាលក្រម *Stakic* កថាខ័ណ្ឌ៤៤៥។ សាលក្រម *Kordic* កថាខ័ណ្ឌ៣៨៨។

[152] សាលក្រម *Blaskic* កថាខ័ណ្ឌ២៧៨។ សាលក្រម *Bagilishema* កថាខ័ណ្ឌ៣១។

[153] សាលដីកា *Blaskic* កថាខ័ណ្ឌ៤២។ សាលដីកា *Kordic* កថាខ័ណ្ឌ២៩-៣០។

[154] សាលក្រម *Aleksovski* កថាខ័ណ្ឌ៨៩។

[155] សាលក្រម *Aleksovski* កថាខ័ណ្ឌ៨៨។

ដែរ ដោយសារតែគាត់បានបញ្ជាឱ្យឆ្មាំពន្ធនាគារបន្តវាយដំជនជាប់ឃុំឃាំង ពេលដែលឆ្មាំពន្ធនាគារបានឈប់វាយពួកគេទៅហើយ[156]។

### ៣. បានធ្វើផែនការ

៥៣. ការធ្វើផែនការឧក្រិដ្ឋកម្មណាមួយ "មានន័យថា មនុស្សម្នាក់ ឬច្រើននាក់ គិតគូរពិចារណាដើម្បីរៀបចំគំរោងការណ៍ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ទាំងនៅក្នុងដំណាក់កាលរៀបចំ និងទាំងនៅក្នុងដំណាក់កាលអនុវត្តផង"[157]។ អំពើនៃការរៀបចំផែនការឧក្រិដ្ឋកម្មណាមួយត្រូវតែ "មានសារៈសំខាន់" គ្រប់គ្រាន់ ដើម្បីធ្វើយុត្តិកម្មអំពីការទទួលខុសត្រូវលើអំពើឧក្រិដ្ឋជាបុគ្គល ដូចជា "ការរៀបចំផែនការឧក្រិដ្ឋកម្មណាមួយ ឬការយល់ព្រមទៅលើផែនការឧក្រិដ្ឋកម្មណាមួយដែលជនដទៃទៀតបានស្នើ" [158]។ ភស្តុតាងអំពី "ការរៀបចំផែនការឧក្រិដ្ឋកម្មណាមួយ" អាចជាភស្តុតាងប្រយោលក៏បាន[159]។ លើសពីនេះ តម្រូវឱ្យជនជាប់ចោទត្រូវតែមានចេតនាឧក្រិដ្ឋ ដោយផ្ទាល់ ឬដោយប្រយោលដែលធ្វើឱ្យឧក្រិដ្ឋកម្មដែលបានរៀបចំផែនការរួចហើយនោះត្រូវបានប្រព្រឹត្ត[160]។

### ៤. បានញុះញង់

---

[156] សាលក្រម *Aleksovski* កថាខ័ណ្ឌ៨៨។

[157] សាលក្រម *Krstic* កថាខ័ណ្ឌ៦០១។ *រដ្ឋអាជ្ញា ទល់នឹង Musema* សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា សំណុំរឿងលេខ ICTR-96-3-T ថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខ័ណ្ឌ១១៩ ("សាលក្រម *Musema*")។

[158] សាលក្រម *Bagilishema* កថាខ័ណ្ឌ៣០។ *រដ្ឋអាជ្ញា ទល់នឹង Semanza* សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា សំណុំរឿងលេខ ICTR-97-20-T -T ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខ័ណ្ឌ៣៨០ ("សាលក្រម *Semanza*")។

[159] សាលក្រម *Blaskic* កថាខ័ណ្ឌ២៧០។ សាលក្រម *Kajelijeli* កថាខ័ណ្ឌ៧៦១។

[160] សាលក្រម *Blaskic* កថាខ័ណ្ឌ២៧៨។ សាលក្រម *Bagilishema* កថាខ័ណ្ឌ៣១។

៥៤. ការញុះញង់(Instigating) ឱ្យមានបទឧក្រិដ្ឋមានន័យថា "ដាស់តឿន(prompt) ជនណាម្នាក់ផ្សេងទៀតឱ្យប្រព្រឹត្តបទឧក្រិដ្ឋ" ហើយមានន័យដូចគ្នានឹងពាក្យ "បង្ក(provoke)" និង "ញុះញង់(incite)"[161]។ *អំពើពិរុទ្ធ(actus rus)* នៃការញុះញង់គឺ "ការបញ្ចុះបញ្ចូល(urging) ការលើកទឹកចិត្ត(encouraging) ឬការដាស់តឿន/ក្រើនរំឭក(prompting)[162]។ ទំនាក់ទំនងហេតុនិងផលរវាងការញុះញង់ និង ឧក្រិដ្ឋកម្មជាមូលដ្ឋាន(មួយឬច្រើន) គឺជាការចាំបាច់ណាស់[163]។ ការញុះញង់តោងតែជា"កត្តារួមចំណែកមួយយ៉ាងច្បាស់លាស់ដល់អំពើប្រព្រឹត្តរបស់ជនដែលជាក់ស្តែងបានប្រព្រឹត្តអំពើឧក្រិដ្ឋនោះ"[164]។ ការញុះញង់ អាចជាអំពើឬការខកខានមិនបានធ្វើអំពើណាមួយ[165]។ ការដែលគ្រាន់តែមានវត្តមានរបស់ជនដែលមានអំណាចណាម្នាក់ ដែលខកខានមិនបានធ្វើអំពើតែប៉ុណ្ណោះក៏ត្រូវចាត់ទុកជាអំពើនៃការញុះញង់មួយដែរ[166]។ បើនិយាយអំពីធាតុផ្សំនៃ*ចេតនាឧក្រិដ្ឋ (mens rea)* គឺតម្រូវឱ្យបង្ហាញថាជនជាប់ចោទ "បានមានចេតនាបង្ក ឬអុចអាលឱ្យប្រព្រឹត្តបទឧក្រិដ្ឋនោះ"។ ការដឹងអំពីភវនីយភាពដែលថា ឧក្រិដ្ឋកម្មមួយឬច្រើនប្រាកដជានឹងកើតឡើងដោយសារតែផលវិបាកបណ្តាលមកពីអំពើរបស់ជនជាប់ចោទ គឺជាការគ្រប់គ្រាន់[167]។

៥៥. យុត្តិសាស្ត្រដែលទាក់ទងយ៉ាងជាក់លាក់ទៅនឹងមណ្ឌលឃុំឃាំង បានឱ្យដឹងថា មណ្ឌលឃុំឃាំងនានាបានរកឃើញថា បុគ្គលិកនៃមណ្ឌលឃុំឃាំងទាំងនោះគឺជាអ្នកទទួលខុសត្រូវចំពោះការញុះញង់ឱ្យមានប្រព្រឹត្តកម្មឃោរឃៅមកលើជនជាប់ឃុំឃាំងនៅក្នុងពេលសួរចម្លើយ និងក្នុងពេលឃុំឃាំង ដោយការនាំឆ្មាំយាមមួយចំនួនដែលបានវាយដំជនជាប់ឃុំឃាំងមកកាន់បន្ទប់ឃុំឃាំងរបស់ជនជាប់ឃុំឃាំងទាំង

---

[161] សាលក្រម *Krstic* កថាខ័ណ្ឌ៦០១។ សាលក្រម *Blaskic* កថាខ័ណ្ឌ២៨០។ សាលដីកា *Akayesu* កថាខ័ណ្ឌ៤៧៤-៤៨៣។

[162] សាលក្រម *Semanza* កថាខ័ណ្ឌ៣៨១។

[163] សាលក្រម *Bagilishema* កថាខ័ណ្ឌ៣០។ សាលក្រម *Semanza* កថាខ័ណ្ឌ៣៨១។ សាលក្រម *Blaskic* កថាខ័ណ្ឌ ២៨០។

[164] សាលក្រម *Kvocka* កថាខ័ណ្ឌ២៥២។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង* *Ndindabahizi* សាលក្រម និងការផ្តន្ទាទោស តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា សំណុំរឿងលេខ ICTR-2001-71-I ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ កថាខ័ណ្ឌ៤៥៦ ('សាលក្រម *Ndindabahizi*')។

[165] សាលក្រម *Kordic* កថាខ័ណ្ឌ៣៨៧។ សាលក្រម *Blaskic* កថាខ័ណ្ឌ ២៨០។

[166] សាលក្រម *Musema* កថាខ័ណ្ឌ៨៦៥ ៨៩៤។

[167] សាលក្រម *Naletilic* កថាខ័ណ្ឌ៦០ *Blaskic* សាលក្រម កថាខ័ណ្ឌ២៧៨ សាលក្រម *Bagilishema* កថាខ័ណ្ឌ ៣១ សាលក្រម *Akayesu* កថាខ័ណ្ឌ៤៨២។

នោះ ហើយបុគ្គលិកទាំងនោះបាននៅស្ងៀមនៅពេលដែលពួកគេគួរតែអាចធ្វើការជំទាស់ ឬបង្ក្រាបទៅលើប្រព្រឹត្តកម្មដោយបំពានទាំងនោះបាន[168]។ មេបញ្ជាការពន្ធនាគារទាំងឡាយ ក៏ត្រូវបានចាប់បង្ខំឱ្យទទួលខុសត្រូវចំពោះការញុះញង់ឱ្យមានការធ្វើទុក្ខបុកម្នេញ អំពើឃាតកម្ម ការធ្វើទារុណកម្ម និងការវាយដំជនជាប់ឃុំឃាំងដែរ ដោយសារតែមិនបានចាត់វិធានការក្នុងពេលដែលខ្លួនស្ថិតក្នុងមុខតំណែងមានអំណាចនិងឥទ្ធិពល[169] និងដោយសារតែមេបញ្ជាការពន្ធនាគារ "ការយល់ព្រម ការលើកទឹកចិត្ត ការសុខចិត្តបណ្តោយតាមគេដោយស្ងៀមស្ងាត់ និងការជួយឧបត្ថម្ភក្នុងការធ្វើឱ្យមានការរីកចម្រើន និងការបន្តឱ្យមានស្ថានភាពបែបនេះនៅក្នុងមណ្ឌលឃុំឃាំង និងឱ្យមានការប្រព្រឹត្តិអំពើឧក្រិដ្ឋទាំងនេះជាបន្តទៅទៀត ចំពោះអ្នកទោសនៅក្នុងពន្ធនាគារ[170]។

## ៥. បានជួយជ្រោមជ្រែង

៥៦. ការជួយជ្រោមជ្រែងឱ្យអំពើឧក្រិដ្ឋណាមួយកើតឡើង ត្រូវបានគេស្គាល់ម្យ៉ាងទៀតថា គឺជាការទទួលខុសត្រូវបន្ទាប់បន្សំ ឬការទទួលខុសត្រូវនៅក្នុងការសមគំនិត។ ជួយជ្រោមជ្រែង គឺមានន័យថាផ្តល់ "ការជួយឧបត្ថម្ភ ការលើកទឹកចិត្ត ឬការជួយគាំទ្រខាងស្មារតីដោយជាក់ស្តែង" ដល់ចារីដែល "ចូលរួមចំណែកយ៉ាងសំខាន់" ដល់ការប្រព្រឹត្តិអំពើឧក្រិដ្ឋ[171]។ ការចូលរួមចំណែកដ៏សំខាន់ គឺមានន័យថា មានភាវនីយភាពខ្លាំងបំផុតថា ឧក្រិដ្ឋកម្មមុខជានឹងមិនកើតឡើងតាមរបៀបដែលទេ ប្រសិនជាមិនមានការចូលរួមចំណែករបស់ជនជាប់ចោទទេនោះ[172]។ ទោះជាយ៉ាងនេះក៏ដោយ តួនាទីរបស់

---

[168] សាលក្រម *Aleksovski* កថាខ័ណ្ឌ៨៨។

[169] សាលក្រម *Kvocka* កថាខ័ណ្ឌ៤០៩។

[170] សាលក្រម *Kvocka* កថាខ័ណ្ឌ ៣៦៨ ៣៩៣ ៣៩៥។

[171] សាលដីកា *រដ្ឋអាជ្ញា ទល់នឹង Aleksovski* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ. IT-95-14/1 ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខ័ណ្ឌ១៦២ ("សាលដីកា *Aleksovski*")។ សាលដីកា *Blaskic* កថាខ័ណ្ឌ៤៦។ ទោះបីជាយ៉ាងណាក៏ដោយ ទំនាក់ទំនងរវាង ហេតុ និងផលចំពោះឧក្រិដ្ឋកម្មសំខាន់ដូច្នេះមិនចាំបាច់ទេ: សាលក្រម *Krnojelac* កថាខ័ណ្ឌ៨៨។ សាលក្រម *Kunarac* កថាខ័ណ្ឌ៣៩១។ សាលក្រម *Blaskic* កថាខ័ណ្ឌ២៨៥។

[172] សាលក្រម *រដ្ឋអាជ្ញា ទល់នឹង Dusko Tadic* អង្គជំនុំជម្រះសាលាដំបូង តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-94-1-T ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខ័ណ្ឌ ៦៨៨ ("សាលក្រម *Tadic*")។

ជនជាប់ចោទ មិនចាំបាច់តម្រូវថាជាតួនាទីដែលសំខាន់ចាំបាច់ខានមិនបាននោះទេ[173]។ ការដែលគ្រាន់តែមានវត្តមានរបស់ជនជាប់ចោទតែប៉ុណ្ណោះ ក៏ជាអំពើជួយជ្រោមជ្រែងរួចជាស្រេចទៅហើយ ប្រសិនបើវត្តមានរបស់គាត់បង្ហាញថា បានជួយលើកទឹកចិត្តដ៏មានសារៈសំខាន់ដល់ចារីពិតប្រាកដមែននោះ[174] ការជួយជ្រោមជ្រែង អាចកើតឡើង នៅមុនពេល ក្នុងពេល និងក្រោយពេលដែលអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្ត[175]។ រីឯការជួយជ្រោមជ្រែងឱ្យមានអំពើឧក្រិដ្ឋកើតឡើង ចាំបាច់តម្រូវឱ្យបង្ហាញភស្តុតាងច្បាស់លាស់នៅឯសវនាការបង្ហាញថា ឧក្រិដ្ឋកម្មជាមូលដ្ឋាន ដែលមានការជួយជ្រោមជ្រែងនោះពិតជាបានប្រព្រឹត្តមែន[176] ប៉ុន្តែការបង្ហាញឱ្យឃើញថាមានការជួយជ្រោមជ្រែងនេះ មិនត្រូវផ្សារភ្ជាប់គ្នាទៅនឹងការចោទប្រកាន់ ឬការផ្តន្ទាទោសនៅក្នុងពេលដំណាលគ្នាចំពោះចារីម្នាក់ ឬច្រើននាក់ ដែលជាអ្នកប្រព្រឹត្តដោយផ្ទាល់នោះទេ។

៥៧. ចំពោះចេតនាឧក្រិដ្ឋដែលតម្រូវឱ្យមាន គឺមិនចាំបាច់តម្រូវឱ្យជនជាប់ចោទ "រួមចំណែក" នៅក្នុង *ចេតនាឧក្រិដ្ឋ (mens rea)* រួមគ្នាជាមួយចេតនារបស់ចារីនោះទេ[177] ឬក៏មិនចាំបាច់ដឹងឱ្យបានច្បាស់លាស់អំពីអំពើឧក្រិដ្ឋមួយឬច្រើនដែលចារីមានចេតនាចង់ប្រព្រឹត្ត ឬជាក់ស្តែងបានប្រព្រឹត្តរួចហើយនោះដែរ[178]។ ក៏ប៉ុន្តែ ជនជាប់ចោទត្រូវតែ (១) ដឹង ឬមានអារម្មណ៍ដឹងថា អំពើរបស់

---

[173] សាលក្រម *រដ្ឋអាជ្ញា ទល់នឹង Anto Furundzija*, , អង្គជំនុំជម្រះសាលាដំបូង តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខៈ IT-95-17/1-T ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខ័ណ្ឌ២០៩ ("សាលក្រម *Furundzija*") សាលក្រម *Bagilishema* កថាខ័ណ្ឌ៣៣។

[174] សាលក្រម *Vasiljevic* កថាខ័ណ្ឌ៧០។ សាលក្រម *Aleksovski* កថាខ័ណ្ឌ ៦៤-៦៥។ សាលក្រម *Blaskic* កថាខ័ណ្ឌ២៨៤។

[175] សាលដីកា *Blaskic* កថាខ័ណ្ឌ៤៨។ សាលក្រម *Aleksovski* កថាខ័ណ្ឌ៦២។

[176] សាលក្រម *Stakic* កថាខ័ណ្ឌ៥៦១។ សាលក្រម *Blagojevic* កថាខ័ណ្ឌ៦៣៨។ សាលក្រម *Musema* កថាខ័ណ្ឌ១៧១-១៧២។

[177] សាលដីកា *Aleksovski* កថាខ័ណ្ឌ១៦២។ សាលក្រម *Vasiljevic* កថាខ័ណ្ឌ៧១។ សាលក្រម *Semanza* កថាខ័ណ្ឌ៣៨៨។ សាលក្រម *Kunarac* កថាខ័ណ្ឌ ៣៩២។

[178] សាលក្រម *Blaskic* កថាខ័ណ្ឌ២៨៧ សាលក្រម *Kvocka* កថាខ័ណ្ឌ២៥៥។

គាត់នឹងជួយជំរុញឲ្យមានការប្រព្រឹត្តិអំពើឧក្រិដ្ឋមួយឬច្រើន[179]។ (២) មានអារម្មណ៍ដឹងអំពីធាតុផ្សំសំខាន់ៗនៃបទឧក្រិដ្ឋ និង (៣) ដឹងអំពីចេតនារបស់ចារីម្នាក់ ឬច្រើននាក់[180]។

៥៨. យុត្តិសាស្ត្រដែលទាក់ទងជាក់លាក់ទៅនឹងមណ្ឌលឃុំឃាំងនានា បានរកឃើញថា ចុងចោទទាំងឡាយគឺជាអ្នកទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដោយសារតែពួកគេបានជួយជ្រោមជ្រែងឲ្យមាន "អំពើឃោរឃៅផ្សេងៗ" និងអំពើហិង្សានានានៅក្នុងពន្ធនាគារ[181]។ ក្នុងករណីរឿងក្តីរបស់ *Aleksovski* ជនជាប់ចោទត្រូវបានគេរកឃើញថា បាននាំឆ្មាំពន្ធនាគារទៅកាន់បន្ទប់របស់ជនជាប់ឃុំឃាំងហើយឆ្មាំទាំងនោះក៏បានវាយដំជនជាប់ឃុំឃាំងទាំងនោះ ជាបន្ថែមពីលើការមានវត្តមានម្តងម្កាលរបស់ជនជាប់ចោទក្នុងពេលគេកំពុងវាយដំដែលតែងមានជាញឹកញាប់ ឬក្នុងពេលគាត់កំពុងស្ថិតនៅជិតខាងក្បែរៗការិយាល័យរបស់គាត់។ វត្តមានរបស់ជនជាប់ចោទនៅក្នុងពេលប្រព្រឹត្តអំពើឃោរឃៅដែលមានលក្ខណៈជាប្រព័ន្ធមកលើជនជាប់ឃុំឃាំង ជាការដែលអាចធ្វើឲ្យទាញជាសេចក្តីសន្និដ្ឋានបានថា ជនជាប់ចោទបានដឹងថាការយល់ព្រមដោយស្ងៀមស្ងាត់គឺត្រូវបានបកស្រាយថា គឺជាសញ្ញានៃការគាំទ្រ និងការលើកទឹកចិត្ត[182]។

## ៦. ការទទួលខុសត្រូវរបស់ថ្នាក់លើ

៥៩. ការទទួលខុសត្រូវរបស់ថ្នាក់លើ ឬមេបញ្ជាការ គឺជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលមានចែងយ៉ាងច្បាស់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់អនុសញ្ញាអន្តរជាតិ[183] ដែលត្រូវ

---

[179] សាលដីកា *Aleksovski* កថាខ័ណ្ឌ១៦២។ សាលដីកា*Blaskic* កថាខ័ណ្ឌ៤៦ ៤៩-៥០។ សាលដីកា *Tadic* កថាខ័ណ្ឌ២២៩។ សាលក្រម *Vasiljevic* កថាខ័ណ្ឌ៧១។

[180] សាលដីកា *Aleksovski* កថាខ័ណ្ឌ១៦២។ សាលក្រម *Kunarac* កថាខ័ណ្ឌ៣៩២។ សាលក្រម *Kvocka,* កថាខ័ណ្ឌ២៥៥ ២៦២។ សាលក្រម *Krnojelac* កថាខ័ណ្ឌ៩០។

[181] សាលក្រម *Aleksovski* កថាខ័ណ្ឌ៨៨។

[182] សាលក្រម *Aleksovski* កថាខ័ណ្ឌ៨៧។

[183] *រដ្ឋអាជ្ញា ទល់នឹង* *Delalic* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការសាលាឧទ្ធរណ៍ សំណុំរឿងលេខ IT -96-21-A ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខ័ណ្ឌ១៩៥ ("សាលដីកា *Delalic*")។

បានគេយកមកអនុវត្ត ដោយមិនគិតពីទីកន្លែងនៃជម្លោះជាដើមអាទិ៍នោះទេ ទោះបីជាជម្លោះផ្ទៃក្នុង ឬជាអន្តរជាតិក៏ដោយ[184]។ ដើម្បីបង្ហាញភស្តុតាងឱ្យឃើញអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើចាំបាច់ត្រូវតែបំពេញឱ្យបានគ្រប់គ្រាន់នូវធាតុផ្សំចំនួន៣ ដូចខាងក្រោមនេះ អំពី៖

(ក) ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់។

(ខ) ថ្នាក់លើបានដឹង ឬមានហេតុផលត្រូវដឹងថា អ្នកក្រោមបង្គាប់របស់គាត់បានប្រព្រឹត្តអំពើឧក្រិដ្ឋ ឬបំរុងនឹងប្រព្រឹត្តអំពើឧក្រិដ្ឋណាមួយ។

(គ) ថ្នាក់លើខកខានមិនបានទប់ស្កាត់កុំឱ្យឧក្រិដ្ឋកម្មកើតឡើង ឬមិនបានដាក់ទណ្ឌកម្មទៅលើចារីទេ[185]។

៦០. ចំពោះធាតុផ្សំទី១ ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់អាចមានអត្ថិភាព ជាផ្លូវការឬក្រៅផ្លូវការ ដោយផ្ទាល់ ឬដោយប្រយោល រវាងជនជាប់ចោទ និងចារីម្នាក់ឬច្រើននាក់ដែលត្រូវចោទអំពីបទឧក្រិដ្ឋ[186]។ ចាំបាច់តម្រូវឱ្យជនជាប់ចោទមានសិទ្ធិអំណាច *ដាក់ស្តែងឬស្របច្បាប់* ទៅលើចារីនោះឬទាំងនោះ[187] ដែលអាចអនុវត្តចំពោះជនស៊ីវិលក៏ដូចជាមេបញ្ជាការយោធានានាបាន ឱ្យតែជនស៊ីវិល

[184] *រដ្ឋអាជ្ញា ទល់នឹង Hadzihasanovic និងអ្នកដទៃទៀត* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ចាត់របៀប លើបញ្ហាយុត្តាធិការលើភារៈទទួលខុសត្រូវរបស់ថ្នាក់លើ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-01-47-AR72 ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខ័ណ្ឌ១៣ ៣១ ១៦ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ *Hadzinhasanovic*")។

[185] *Aleksovski* សាលដីកា កថាខ័ណ្ឌ៧២ ៧៦។ *រដ្ឋអាជ្ញា ទល់នឹង Bagilishema* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា សំណុំរឿងលេខ ICTR-95-1A-A ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២ កថាខ័ណ្ឌ២៤-៣៨ ("សាលដីកា *Bailishema*")។ សាលដីកា *Delalic* កថាខ័ណ្ឌ១៨៩-១៩៨ ២២៥-២២៦ ២៣៨-២៣៩ ២៥៦ ២៦៣។

[186] សាលដីកា *Delalic* កថាខ័ណ្ឌ២៥១-២៥២ ៣០៣។ សាលក្រម *Krnojelac* កថាខ័ណ្ឌ៩៣។ សាលក្រម *Kordic* កថាខ័ណ្ឌ៤១៦។

[187] សាលដីកា *Delalic* កថាខ័ណ្ឌ១៩៣ ១៩៧។ *រដ្ឋអាជ្ញា ទល់នឹង Niyitegeka* សាលក្រម និងការផ្តន្ទាទោស អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា សំណុំរឿងលេខ ICTR-96-14-T ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០០៣ កថាខ័ណ្ឌ៤៧២ ("សាលក្រម *Niyitegeka*")។

00364884

E153



ទាំងនោះប្រើប្រាស់អំណាចត្រួតត្រា ប្រហាក់ប្រហែលគ្នានឹងអំណាចរបស់មេបញ្ជាការយោធា[188]។ ទំនាក់ទំនងរវាងថ្នាក់លើនិងអ្នកក្រោមបង្គាប់មានអត្ថិភាព ប្រសិនបើជនជាប់ចោទមាន "ការត្រួតត្រាដោយមានប្រសិទ្ធភាព" ទៅលើចារីទាំងនោះ មានន័យថា ជនជាប់ចោទគួរតែបានធ្វើការទប់ស្កាត់កុំឱ្យឧក្រិដ្ឋកម្មទាំងនោះកើតឡើងឬគួរតែបានធ្វើការដាក់ទណ្ឌកម្មចំពោះចារីណាដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ[189]។ ការត្រួតត្រាដោយមានប្រសិទ្ធភាពនេះ ត្រូវតែខ្លាំងជាងការដែលគ្រាន់តែមានឥទ្ធិពលដ៏សំខាន់[190]។ ជនជាប់ចោទម្នាក់អាចមាន "ការត្រួតត្រាដោយមានប្រសិទ្ធភាព" ជាអចិន្ត្រៃយ៍ ឬជាបណ្ដោះអាសន្នទៅលើចារី ប៉ុន្តែការត្រួតត្រាដោយមានប្រសិទ្ធភាពនេះ ត្រូវតែមានអត្ថិភាពនៅក្នុងអំឡុងពេលប្រព្រឹត្តអំពើឧក្រិដ្ឋនោះឬទាំងនោះ[191]។

៦១. ជនជាប់ចោទបានខកខានមិនបានទប់ស្កាត់អំពើឧក្រិដ្ឋ ឬមិនបានដាក់ទណ្ឌកម្ម នៅពេលដែលគាត់មិនបានចាត់ "វិធានការចាំបាច់និងសមស្រប ដើម្បីទប់ស្កាត់អំពើឧក្រិដ្ឋ ឬដាក់ទណ្ឌកម្មចំពោះអ្នកក្រោមបង្គាប់របស់គាត់ដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ"[192]។ ការសម្រេចរបស់ជនជាប់ចោទដោយខ្លួនឯងផ្ទាល់មួយក្នុងការចាត់វិធានការផ្សេងៗគួរតែបានធ្វើឡើង ស្របទៅតាមអ្វីដែលច្បាប់បានតម្រូវឱ្យខ្លួនម្នាក់ៗត្រូវតែធ្វើ[193] ក៏ប៉ុន្តែក៏មានកាតព្វកិច្ចជាមូលដ្ឋានមួយចំនួនដែលថ្នាក់ លើម្នាក់ៗត្រូវតែធ្វើតាមដែរ។ ជាតម្រូវការជាអប្បបរមាមួយនោះ គឺជនជាប់ចោទត្រូវតែធ្វើការ"ស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មនោះ ដើម្បីរកអង្គហេតុ និងដើម្បីធ្វើរបាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើគាត់មិនអាចមានសិទ្ធិអំណាចក្នុងការសម្រេចដោយខ្លួនឯង[194]។ ថ្នាក់លើអាចនឹងតម្រូវឱ្យធ្វើហួសពីទម្រង់

---

[188] សាលដីកា *Bagilishema* កថាខ័ណ្ឌ៥១-៥៥ សាលដីកា *Delalic* កថាខ័ណ្ឌ១៩៦ សាលដីកា *Aleksovski* កថាខ័ណ្ឌ ៧៦។

[189] សាលដីកា *Blaskic* កថាខ័ណ្ឌ៣៧៥។ សាលដីកា *Bagilishema* កថាខ័ណ្ឌ៥០ ៥៦។ សាលដីកា *Delalic* កថាខ័ណ្ឌ២៥៦។ សាលដីកា *Kayishema* កថាខ័ណ្ឌ២៩៤។ សាលដីកា *Aleksovski* កថាខ័ណ្ឌ៧៦ ព្រមទាំងសាលដីកា លើលទ្ធភាពដែលអាចប្រព្រឹត្តៈ *Blaskic* សាលដីកា កថាខ័ណ្ឌ៧២៤១៧ សាលក្រម *Bagilishema* កថាខ័ណ្ឌ៤៧។

[190] សាលដីកា *Delalic* កថាខ័ណ្ឌ២៥៧-២៦៦។

[191] សាលក្រម *Kunarac* កថាខ័ណ្ឌ៣៩៩។ សាលក្រម *Blaskic* កថាខ័ណ្ឌ៣០៣។ សាលក្រម *Aleksovki* កថាខ័ណ្ឌ១០៦។

[192] សាលដីកា *Delalic* កថាខ័ណ្ឌ២២៦។

[193] សាលដីកា *Blaskic* កថាខ័ណ្ឌ៧២។ សាលក្រម *Brdanin* កថាខ័ណ្ឌ២៧៩។

[194] សាលក្រម *Kordic* កថាខ័ណ្ឌ៤៤៦។

ការតាមផ្លូវច្បាប់និងរចនាសម្ព័ន្ធ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់អំពើឧក្រិដ្ឋកុំឱ្យកើតឡើង ឬ ដាក់ទណ្ឌកម្មចំពោះចារីដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋនោះ[195]។ ការខកខានមិនបានទប់ស្កាត់ ឬមិនបាន ដាក់ទណ្ឌកម្ម គឺពិតជាលទ្ធផលដែលកើតមកពីការសម្រេចដោយគិតទុកជាមុន ដោយមានពិរុទ្ធ និង ដោយចេតនា ក្នុងការជ្រើសរើស ពីសំណាក់ជនជាប់ចោទដោយមិនគោរពទៅតាមតួនាទីរបស់ខ្លួន[196]។ ការដែលគ្រាន់តែធ្វេសប្រហែសតែប៉ុណ្ណោះគឺវាមិនគ្រប់គ្រាន់ទេ[197]។

៦២. ទាំងមេបញ្ជាការស៊ីវិល និងមេបញ្ជាការយោធា ធាតុផ្សំខាងចេតនាក្នុងការទទួលខុសត្រូវរបស់ថ្នាក់លើ ចាំបាច់តម្រូវឱ្យជនជាប់ចោទបានដឹង និងមានហេតុផលដឹងថា អ្នកក្រោមបង្គាប់របស់ខ្លួនបម្រុងនឹង ប្រព្រឹត្ត ឬបានប្រព្រឹត្តអំពើឧក្រិដ្ឋរួចហើយ[198]។ "បានដឹង" (knew) មានន័យថា ដឹងពិតប្រាកដ (actual knowledge) ចំណែកឯ "មានហេតុផលដឹង" (had reason to know) មានន័យថា ជនជាប់ចោទ "មានព័ត៌មានក្នុងរូបភាពណាមួយនៅក្នុងដៃដែលយ៉ាងហោចណាស់ ក៏អាចជូនដំណឹង ឱ្យគាត់ដឹងអំពីហានិភ័យនៃឧក្រិដ្ឋកម្មទាំងនោះ ដែលបញ្ជាក់ថាចាំបាច់ត្រូវតែធ្វើការស៊ើបអង្កេតបន្ថែម ទៀតដើម្បីឱ្យដឹងប្រាកដថាតើឧក្រិដ្ឋកម្មនោះពិតជាបានប្រព្រឹត្តរួចហើយ ឬបានបម្រុងនឹងប្រព្រឹត្ត ដោយអ្នកក្រោមបង្គាប់របស់គាត់ពិតមែនដែរឬទេ?[199]។ ជនជាប់ចោទមិនត្រូវមានចេតនា ខកខានមិន បំពេញតាមតួនាទីរបស់ខ្លួនក្នុងនាមជាថ្នាក់លើមួយរូបដោយការធ្វើមិនដឹងមិនឮ ឬមិនគោរពចំពោះ ភស្តុតាងអំពីសកម្មភាពនៃអំពើឧក្រិដ្ឋណាមួយនោះបានទេ[200]។ ការដឹង[201] ត្រូវតែមានទំនាក់ទំនងគ្នា ទៅវិញទៅមកជាមួយនឹងអំពើឧក្រិដ្ឋ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះ[202]។

---

[195] សាលដីកា *Kayishema* កថាខ័ណ្ឌ៣០២។ សាលក្រម *Delalic* កថាខ័ណ្ឌ៣៩៥។

[196] សាលដីកា *Bagilishema* កថាខ័ណ្ឌ៣៥ ៣៦។

[197] សាលដីកា *Blaskic* កថាខ័ណ្ឌ៦១-៦៣។ សាលដីកា *Bagilishema* កថាខ័ណ្ឌ៣៥។ សាលដីកា *Delalic* កថាខ័ណ្ឌ២២៦។

[198] សាលដីកា*Blaskic* កថាខ័ណ្ឌ៥៤-៦៤។ សាលដីកា *Delalic* កថាខ័ណ្ឌ១៩៦-១៩៧ ២៣៩-២៤១។ សាលដីកា *Aleksovski* កថាខ័ណ្ឌ៧២ ៧៦។

[199] សាលដីកា *Delalic* កថាខ័ណ្ឌ ២៤១ សាលដីកា *Baglishema* កថាខ័ណ្ឌ២៦-៣៨ ៤២។

[200] សាលដីកា *Blaskic* កថាខ័ណ្ឌ២៤១។

[201] ការដឹងឮអាចបានត្រូវបង្ហាញតាមរយៈភស្តុតាងជាក់ស្តែង ឬតាមកាលៈទេសៈ។ *សូមមើល* សាលក្រម *Blaskic* កថាខ័ណ្ឌ៣០៨។ សាលក្រម *Krnojelac* កថាខ័ណ្ឌ៩៤។ សាលក្រម*Aleksovski* កថាខ័ណ្ឌ៨០ សម្រាប់យុត្តិសាស្ត្រ ដែលទាក់ទង

៦៣. យុត្តិសាស្ត្រដែលទាក់ទងយ៉ាងជាក់លាក់ទៅនឹងមណ្ឌលឃុំឃាំងនានា បានរកឃើញថា ជនជាប់ចោទមានហេតុផលត្រូវតែដឹងថា ឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនបានកើតឡើងក្នុងមន្ទីរឃុំឃាំង ដោយបរិបទខាងក្រៅ (ពោលគឺ មូលហេតុដែលនាំឱ្យមានការបង្កើតពន្ធនាគារ) និងដោយបរិបទខាងក្នុង (ពោលគឺ ដំណើរការរបស់ពន្ធនាគារ ជាពិសេសគឺភាពរីករាលដាលនៃការវាយដំ និងភាពញឹកញាប់នៃការសួរចម្លើយ)[203]។ មេបញ្ជាការមណ្ឌលឃុំឃាំងទាំងឡាយត្រូវបានគេរកឃើញថា ជាអ្នកមានការត្រួតត្រាដោយប្រសិទ្ធភាព ព្រោះពួកគេគឺជាអ្នកដែលមានអំណាចចេញបញ្ជាទៅដល់អ្នកនៅក្រោមបង្គាប់របស់ខ្លួន[204] ជាអ្នកដែលបានកាន់មុខនាទីខ្ពង់ខ្ពស់ក្នុងពន្ធនាគារ ហើយមានសិទ្ធិក្នុងការធ្វើរបាយការណ៍អំពីបទល្មើសផ្សេងៗដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់ខ្លួន ដើម្បីរាយការណ៍បន្តទៅឱ្យសមត្ថកិច្ចថ្នាក់លើ[205]។

## សេចក្តីសន្និដ្ឋាន

៦៤. សហព្រះរាជអាជ្ញា ស្នើដល់អង្គជំនុំជម្រះសាលាដំបូង ពិចារណានៅលើច្បាប់នេះ នៅក្នុងការកំណត់សម្រេចអំពីបទចោទប្រឆាំងនឹង **ឌុច** ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ | លោក យ៉េត ចរិយា<br>**សហព្រះរាជអាជ្ញារង** | ភ្នំពេញ | |
| | លោក William SMITH<br>**សហព្រះរាជអាជ្ញារង** | ភ្នំពេញ | |

អំពីកត្តាក្នុងការកំណត់ថាតើជនត្រូវចោទបានដឹង ឬមានហេតុផលដើម្បីដឹងថាឧក្រិដ្ឋកម្ម បានត្រូវប្រព្រឹត្តឬ នឹងត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់ខ្លួន។ *សូមមើល* សាលក្រម *Kordic* កថាខ័ណ្ឌ៤២៧ ៤៣៧។

[202] សាលដីកា *Krnojelac* កថាខ័ណ្ឌ១៥៥-១៥៦។

[203] សាលក្រម *Krnojelac* បណ្តឹងឧទ្ធរណ៍ កថាខ័ណ្ឌ១៧១។

[204] សាលក្រម *Aleksovsk* កថាខ័ណ្ឌ១០៤។

[205] សាលក្រម *Aleksovski* កថាខ័ណ្ឌ១០៥។